អ្នកឃ្លាំមើល : ការផ្សាយរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា

ខុមហ្វ្រែល COMFREL

ព្រឹត្តិបត្រ ខុមហ្វ្រែល

# អ្នកឃ្លាំមើល
NEAK KLOAMMEUL

លេខ ៤០ ឆ្នាំទី១១ ចេញថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩

## ដើម្បីឱ្យច្បាប់ ឬគោលនយោបាយល្អ ត្រូវតែមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ



## មាតិកា


★ *អធិប្បាយលេខនេះ* ឧបសគ្គនៃការចូលរួមដំណើរការធ្វើច្បាប់ និងគោលនយោបាយ .................................. ១

★ ពានរង្វាន់ប្រចាំឆ្នាំ ២០០៩ សម្រាប់លេខារាជធានី ខេត្តគណៈកម្មាធិការខុមហ្វ្រែល .................................. ៤

★ ការបោះឆ្នោតនៅរដ្ឋហ្វ្ល័រីដា Florida នៃសហរដ្ឋអាមេរិក .................................. ៦

★ ការណែនាំអំពីហិរញ្ញវត្ថុគណបក្សនយោបាយ .................................. ១២

★ សំណឹករឹតតែខ្លាំងឡើងនៃសេរីភាពនៅកម្ពុជា .................................. ១៥

★ កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ ពីខែតុលា ដល់ខែ ធ្នូ ឆ្នាំ២០០៩ .................................. ១៩

*អត្ថាធិប្បាយលេខនេះ*

# ឧបសគ្គនៃការចូលរួមដំណើរការធ្វើច្បាប់ និងគោលនយោបាយ

ដោយមើលឃើញពីភាពអសកម្មចំពោះការអនុវត្តជាក់ស្តែងនៅក្នុងសេណារីយ៉ូ **"ព័ត៌មានសម្ងាត់ ឬមិនបើកចំហ"** ដែលជារឿយៗរដ្ឋាភិបាលតែងយកលេសនេះ មិនអនុញ្ញាតឲ្យស្ថាប័នដែលមានសមត្ថកិច្ចតាក់តែងច្បាប់ ធ្វើការផ្សព្វផ្សាយអំពីដំណើរការ និងអត្ថន័យបញ្ញត្តិនៃសេចក្តីព្រាងច្បាប់ ជាបឋមអ្នកឃ្លាំមើលមានការព្រួយបារម្ភជាខ្លាំងអំពីខ្លឹមសារនៃសេចក្តីព្រាងច្បាប់ និងការអនុម័តវិធានបញ្ញត្តិថ្មីៗ អាចនឹងមានឥទ្ធិពលអវិជ្ជមានក្នុងពេលអនុវត្តជាក់ស្តែង ព្រោះមិនមានការចូលរួមពីប្រជាពលរដ្ឋ សង្គមស៊ីវិល និងគណបក្សនយោបាយផ្សេងៗ ដែលមិនបានឆ្លើយតបទៅនឹងបរិបទពិតប្រាកដក្នុងសង្គមកម្ពុជា ចុងក្រោយច្បាប់ទាំងនោះអាចនឹងក្លាយទៅជា ច្បាប់ខ្វះនីត្យានុកូល។

បើពិនិត្យមើលការតាក់តែងច្បាប់នៅក្នុងប្រទេសប្រជាធិបតេយ្យជឿនលឿន ប្រជាពលរដ្ឋ សង្គមស៊ីវិល និងគណបក្សនយោបាយផ្សេង ត្រូវបានលើកទឹកចិត្ត និងកៀងគរឲ្យចូលរួមក្នុងដំណាក់កាលរៀបចំសេចក្តីព្រាងច្បាប់។



ទិដ្ឋភាពនៃកិច្ចប្រជុំសភាពេញអង្គ

រដ្ឋាភិបាល ឬស្ថាប័ននីតិប្បញ្ញត្តិ ធ្វើការសាកសួរទៅកាន់ពួកគេ ដើម្បីស្វែងយល់អំពីផលប៉ះពាល់ និងជម្រើសផ្សេងៗ មុននឹងរៀបចំគោលនយោបាយសាធារណៈ ឬច្បាប់ដែលមានលក្ខណៈត្រឹមត្រូវទាំងផ្នែកបច្ចេកទេស និងផ្នែកគតិយុត្តិ គោលដៅសំខាន់គឺដើម្បីឲ្យប្រជាពលរដ្ឋដែលស្ថិតនៅក្រោមច្បាប់ អាចយល់ និងអនុវត្តតាមបាន។ របបនយោបាយនៃព្រះរាជាណាចក្រកម្ពុជា ក៏បានទទួលយកនូវគោលគំនិតជឿនលឿននេះមកបញ្ញត្តិសរសេរទុកក្នុងច្បាប់កំពូលរបស់ខ្លួន តាមរយៈមាត្រា៣៥ នៃរដ្ឋធម្មនុញ្ញ បានចែងថា ៖ "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច និងវប្បធម៌របស់ប្រទេសជាតិ" និងមាត្រា៥១ថ្មី នៃរដ្ឋធម្មនុញ្ញ ដដែលបានចែងថា "ប្រជាពលរដ្ឋខ្មែរជាម្ចាស់នៃប្រទេសជាតិរបស់ខ្លួន។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី" ក្នុងន័យនេះបានលើកស្ទួយ និងគាំទ្រការចូលរួមរបស់ពលរដ្ឋលើគ្រប់វិស័យ តែការយល់ដឹង និងការអនុវត្តជាក់ស្តែងនៅមានកម្រិតទាប។

តាមការតាក់តែងច្បាប់ជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ស្របតាមរដ្ឋធម្មនុញ្ញ។ ការរៀបចំច្បាប់ជាក់ស្តែងមាន២យន្តការ ៖ មួយហៅថា សេចក្តីព្រាងច្បាប់ និងមួយទៀតហៅថា សេចក្តីស្នើច្បាប់។ សេចក្តីព្រាងច្បាប់កកើតឡើងពីគំនិតផ្តួចផ្តើមរបស់នាយករដ្ឋមន្ត្រី ក្រោមជំនួយបច្ចេកទេសពីកិច្ចប្រជុំក្រុមការងារនីតិកម្មនៃក្រសួងជំនាញពាក់ពន្ធ័ និងជំនុំក្រុមប្រឹក្សាអ្នកច្បាប់។ សេចក្តីព្រាងច្បាប់ត្រូវឆ្លងកិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យ និងកែសម្រួល ទើបបញ្ជូនទៅគណៈរដ្ឋមន្ត្រីអនុម័ត។ ក្រោយការយល់ព្រមពីគណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រីអាចដាក់សេចក្តីព្រាងច្បាប់ ដោយភ្ជាប់ជាមួយនឹងសេចក្តីថ្លែងហេតុផ្ញើទៅកាន់ប្រធានរដ្ឋសភា។ ចំណែកសេចក្តីស្នើច្បាប់វិញផ្តួចផ្តើមចេញពីតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា ដោយគ្រាន់តែតម្រូវឲ្យក្រុមអ្នកជំនាញច្បាប់ពាក់ពន្ធ័ ប្រជុំពិនិត្យពិភាក្សា អំពីបញ្ហាទាក់ទងនឹងច្បាប់ជាធរមានរហូតដល់ឈានសម្រេចបានជាសេចក្តីស្នើច្បាប់ ទើបបញ្ជូនទៅប្រធានរដ្ឋសភា។ ប្រធានរដ្ឋសភានឹងប្រគល់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ទៅឲ្យគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាពិនិត្យឡើងវិញ។ គណៈកម្មាធិការ

អចិន្ត្រៃយ៍ នឹងបញ្ជូនបន្តទៅគណៈ កម្មការជំនាញ ដើម្បីផ្តល់អនុសាសន៍ មុននឹងបញ្ចូលសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំសភា។ រដ្ឋសភា និងព្រឹទ្ធសភា មានអំណាចអនុម័តកែប្រែចុងក្រោយនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ រួចទើបប្រធានរដ្ឋសភាថ្វាយសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ចំពោះព្រះមហាក្សត្រ។ ព្រះមហាក្សត្រឡាយព្រះហត្ថលេខាលើព្រះរាជក្រម ដើម្បីប្រែក្លាយ សេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ឲ្យទៅជាច្បាប់មួយពិតប្រាកដ។

នៅក្នុងនីតិកាលទី ៤ នៃរដ្ឋសភានេះ សង្គមស៊ីវិលសង្កេតឃើញថា តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមិនបានអើពើចំពោះមតិយោបល់របស់គណបក្សជំទាស់ និងសង្គមស៊ីវិលដែលបានស្នើសុំឲ្យធ្វើការកែប្រែខ្លឹមសារមួយចំនួន ក្នុងពេលអនុម័តសេចក្តីព្រាងច្បាប់នៅសម័យប្រជុំរដ្ឋសភាទេ ព្រោះគណបក្សប្រជាជនមានសមាជិកសភាលើសពី ២ភាគ៣ (៩០អាសនៈនៃចំនួនសរុប១២៣អាសនៈ)។ ក្នុងទិដ្ឋភាពបែបនេះហាក់បីដូចជាចង់បង្ហាញថា ស្ថាប័ននីតិប្បញ្ញត្តិជាកម្មសិទ្ធិផ្តាច់មុខរបស់គណបក្សប្រជាជនកម្ពុជា និងទំនងជាមានបំណងទទួលខុសត្រូវចំពោះប្រវត្តិសាស្ត្រក្នុងការតាក់តែង និងអនុម័តច្បាប់ថ្មីៗតែឯង។ សក្ខីកម្មមួយទៀត គឺតួនាទីរបស់គណៈកម្មការជំនាញទាំង ៩ រួមទាំងគណៈកម្មការអចិន្ត្រៃយ៍ នៃរដ្ឋសភា ពុំមានគណៈកម្មការណាមួយ មានសមាសភាពអ្នកដឹកនាំមកពីគណបក្សសម្លេងភាគតិចឡើយ គណៈកម្មការទាំងអស់ គឺស្ថិតនៅក្រោមការដឹកនាំរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាតែម្នាក់ឯងគត់។ ម៉្យាងទៀត ក្នុងនីតិកាលទី៤ នេះដែរ មានការធ្វើវិសោធនកម្មទៅលើបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាជាពិសេសទៅលើប្រការ៤៨ ថ្មី ដែលបានចែងអំពីការបែងចែកក្រុមអ្នកតំណាងរាស្ត្រសម្រាប់ឡើងមានមតិនៅក្នុងសម័យសភាប្រជុំពេញអង្គ ដោយតម្រូវក្នុងមួយក្រុមមានសមាជិកចំនួន ១០ រូប និងត្រូវមានការយល់ព្រមពីក្រុមទាំងមូលជាមុនសិន ទើបតំណាងរាស្ត្រអាចឡើងមានមតិបាន។ ក្រុមអ្នកវិភាគមួយចំនួនបានលើកឡើងថា វិធាននេះកំពុងប្រើប្រាស់ធ្វើជានីតិវិធីបំបិទសម្លេង ឬសិទ្ធិបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សដែលទទួលបានអាសនៈតិចក្នុងរដ្ឋសភា ឬអាចនិយាយម៉្យាងទៀតថា បានលុបសម្លេងតំណាងពលរដ្ឋម្ចាស់ឆ្នោតរាប់សែននាក់។ ជាក់ស្តែងតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សដែលមានសមាជិកត្រឹមតែ៣រូប មិនដែលបានថ្លែង ឬបញ្ចេញមតិក្នុងពេលប្រជុំសភាបានមួយម៉ាត់ទេ តាំងពីចូលកាន់តំណែងមក ព្រោះហេតុផលតែម៉្យាងគឺនីតិវិធីមិនបានអនុញ្ញាតឲ្យចូលរួម។ នេះគឺបណ្តាលមកពីការផ្លាស់ប្តូរទម្លាប់នៃការបែងចែកអំណាចនៅក្នុងសភា នៅមុនការអនុម័តបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាដែលធ្វើឲ្យអន់ថយនៅក្នុងដំណើរប្រជាធិបតេយ្យនៅក្នុងរដ្ឋសភា និងការបាត់តុល្យភាពអំណាចឯកភាពជាតំណាងប្រជាពលរដ្ឋ។

វាទំនងដូចជាគណបក្សកាន់អំណាចមិនបន្តការយកចិត្តទុកដាក់ ការចូលរួមពីគណបក្សដទៃ និងសង្គមស៊ីវិលមែន ប្រសិនជាយើងពិនិត្យទៅលើខ្លឹមសារនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភាឃើញថា ខុសពីកម្មវិធីនយោបាយរបស់រដ្ឋាភិបាលនីតិកាលទី៣នៃរដ្ឋសភា។ នៅក្នុងកម្មវិធីនយោបាយរបស់រដ្ឋាភិបាលនៃនីតិកាលទី ៣ ដែលកើតចេញពីឆន្ទៈរួមគ្នាពីភាគីនៃគណបក្សជាប់ឆ្នោតមាន ៧៣ ចំណុច ក្នុងនោះបានចែងយ៉ាងច្បាស់អំពីតួនាទីរបស់គណបក្សប្រឆាំង (ចំណុចទី ៩) «...រដ្ឋាភិបាលបន្តគាំទ្រ និងវាយតម្លៃខ្ពស់ចំពោះតួនាទីរបស់មតិប្រឆាំងដែលជាការផ្តល់មតិទិតៀនក្នុងន័យស្ថាបនា...។ រដ្ឋាភិបាលទទួលស្គាល់ជាផ្លូវការនូវអត្ថិភាពគណបក្សប្រឆាំងដោយធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ»។ រីឯចំណុចទី ១០ និងទី ១១ នៃកម្មវិធីនយោបាយនេះដែរមានចែងអំពីការចូលរួមចំណែករបស់សង្គមស៊ីវិល ដែលក្នុងនោះបានចាត់ទុកតួនាទីសង្គមស៊ីវិលជាដៃគូមួយដ៏មានប្រសិទ្ធភាពរបស់រដ្ឋាភិបាលនៅក្នុងការកសាងប្រទេសជាតិ។ ប៉ុន្តែដោយឡែក នៅក្នុងកម្មវិធីនយោបាយរបស់រដ្ឋាភិបាលនីតិកាលទី ៤ នៃរដ្ឋសភា ដែលបានស្តែងចេញពីឆន្ទៈគណបក្សប្រជាជនកម្ពុជាតែមួយ បានបង្រួមមក ៤៨ ចំណុច តែពុំមានចំណុចណាមួយ ឬ«ខ»ណាមួយបានចែងឲ្យច្បាស់អំពីតួនាទីរបស់គណបក្សប្រឆាំង ក៏ដូចជាអំពីការចូលរួម

ចំណែករបស់អង្គការសង្គមស៊ីវិលដែរ។ បើយោងតាមរបាយការណ៍សង្កេតសកម្មភាពសភា និងអ្នកតំណាងរាស្ត្រដែលបានធ្វើឡើងដោយគណៈកម្មាធិការខុមហ្វ្រែល ជារៀងរាល់ខែនោះឃើញថា សម្លេងរបស់អ្នកតំណាងរាស្ត្រគណបក្សកាន់អំណាចបានលុបលើមតិរបស់គណបក្សផ្សេងទៀតគ្រប់ដំណើរការ គណៈកម្មការបច្ចេកទេស និងគណៈកម្មការអចិន្ត្រៃយ៍របស់រដ្ឋសភា ហើយស្ទើរតែគ្រប់សេចក្តីព្រាងច្បាប់ដែលបញ្ជូនមកពីរដ្ឋាភិបាល ត្រូវបានសភាធ្វើការអនុម័តយ៉ាងប្រញាប់ប្រញាល់ (តួយ៉ាង ការពិភាក្សា និងអនុម័តនៅក្នុងប្រជុំពេញអង្គ ៖ សេចក្តីព្រាងច្បាប់ស្តីពីក្រមព្រហ្មទណ្ឌថ្មី ដែលមាន ៦ គន្ថី និង ៦៧២ មាត្រា រដ្ឋសភាអនុម័តក្នុងរយៈពេល ៧ ថ្ងៃ៚ សេចក្តីព្រាងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ដែលមាន ៦ ជំពូក និង ៣០ មាត្រា រដ្ឋសភាអនុម័តក្នុងរយៈពេល ៣ ថ្ងៃ ៚ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងថវិកាជាតិ ឆ្នាំ២០១០ ដែលមាន ៦ ជំពូក និង ២០ មាត្រា រដ្ឋសភាអនុម័តក្នុងរយៈពេល ២ ថ្ងៃ ៚ សេចក្តីព្រាងច្បាប់អស្សាមិករណ៍ ដែលមាន ៨ ជំពូក និង ៣៩ មាត្រា រដ្ឋសភាអនុម័តក្នុងរយៈពេល ២ ថ្ងៃ) ដោយពុំមានការកែសម្រួលទៅលើខ្លឹមសារនៃជំពូក ឬមាត្រាណាមួយនៃសេចក្តីព្រាងច្បាប់ឡើយ ក្រៅតែពីកែអក្ខរាវិរុទ្ធបន្តិចបន្តួចតែប៉ុណ្ណោះ ទោះបីជាមានការបកស្រាយយ៉ាងសមហេតុផល ឬស្នើសុំឲ្យកែប្រែពីសង្គមស៊ីវិល និងគណបក្សជំទាស់យ៉ាងណាក៏ដោយ។

ច្បាប់ភាគច្រើនសុទ្ធតែមានការពាក់ពន្ធ័យ៉ាងសកម្ម និងដោយផ្ទាល់ទៅនឹងជីវភាពប្រជាពលរដ្ឋនេះដូចជាក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ពាក់ពន្ធ័នឹងការពិន័យ និងដាក់ទណ្ឌកម្ម ច្បាប់ស្តីពីហិរញ្ញវត្ថុ ឆ្នាំ២០១០ ដែលក្នុងនោះរួមមានការកំណត់លើការតម្លើងពន្ធអាករ និងការបង្កើតពន្ធថ្មីលើដីធ្លី និងផ្ទះសម្បែង និងសេចក្តីព្រាងច្បាប់ស្តីពីអស្សាមិករណ៍ ដែលគូសវាស់ពីការដកហូតដីធ្លី និងកម្មសិទ្ធិដោយភាគីរដ្ឋយ៉ាងស្របច្បាប់ជាដើម គឺពុំបានបើកចំហឲ្យមានការចូលរួមពីសង្គមស៊ីវិល ក៏ដូចជាប្រជាពលរដ្ឋឲ្យយល់ដឹងបានទូលំទូលាយឡើយ។ យ៉ាងណាមិញ សេចក្តីព្រាងច្បាប់ក្តៅៗស្តីពីច្បាប់ប្រឆាំងអំពើពុករលួយ ដែលត្រូវបានទីស្តីគណៈរដ្ឋមន្ត្រីអនុម័តរួចរាល់កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ មិនត្រូវបានចែកជូនតំណាងរាស្ត្រគណបក្សដែលមានសម្លេងភាគតិច ឬសង្គមស៊ីវិលដើម្បីសិក្សាវិភាគជាមុនទេ ហើយទំនងជាព្យាយាមបំបិទព័ត៌មាន និងអត្ថន័យក្នុងអត្ថបទសេចក្តីព្រាងច្បាប់រហូតដល់វិនាទីចុងក្រោយទើបចម្លងចែកផ្សាយដូចសព្វមួយដង (មិនមានការចូលរួមមតិពីពហុបក្ស) បើទោះបីជាតំណាងរាស្ត្រមកពីគណបក្សដទៃមានសមត្ថកិច្ចតាក់តែងច្បាប់ដូចគ្នាក៏ដោយ។ ក្រុមមន្ត្រីអង្គការសង្គមស៊ីវិលបានលើកឡើងថា ការសម្ងាត់ជុំវិញសេចក្តីព្រាងច្បាប់នេះកំពុងរារាំងការពិភាក្សា និងការវិភាគឲ្យបានត្រឹមត្រូវ។



លោក ស៊ូយ៉ា ស៊ូប៊េឌី

ប៉ុន្តែនៅពេលថ្មីៗនេះ មានសញ្ញាណមួយដែលបានផ្តល់នូវក្តីសង្ឃឹមដល់សង្គមជាតិ នៅពេលដែលប្រមុខរដ្ឋាភិបាល មានការយល់ស្របថា គួរឲ្យមានការជួបពិភាក្សាគ្នា រវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល (ក្នុងឱកាសជំនួបរវាងរាយការណ៍ពិសេសផ្នែកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ លោក ស៊ូយ៉ា ស៊ូប៊េឌី និងលោក នាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីខែមករា ឆ្នាំ២០១០)។ ទោះយ៉ាងណាក៏បញ្ហានេះ ត្រូវបានអ្នកវិភាគស្ថានការណ៍នៅកម្ពុជាវាយតម្លៃថា ត្រូវមានការពិភាក្សាគ្នាអំពីយន្តការមួយចំនួន ដើម្បីឲ្យមានតុល្យភាពក្នុងការពិភាក្សានេះ។

សច្ចធារណ៍រាល់កិច្ចចំពោះមុខក្នុងការតាក់តែងច្បាប់ថាជាកិច្ចសម្ងាត់ទាំងអស់ វាជាឧបសគ្គក្នុងការដុសខាត់ច្បាប់ និងមិនបានផ្តល់ឱកាសឲ្យអ្នកតំណាងរាស្ត្រមកពីគណបក្សជំទាស់ សង្គមស៊ីវិល ឬអ្នកជំនាញការឯករាជ្យ ឬប្រជាពលរដ្ឋនៅតាមមណ្ឌលបានចូលរួមសិក្សា និងវិភាគកែសម្រួល ឬបង្កើតការពិភាក្សាដើម្បីបកស្រាយបញ្ជាក់អំពី

ស្មារតីច្បាប់ក្នុងការអនុវត្តជាក់ស្តែង ដែលបន្ថយការប៉ះពាល់។ ខណៈដែលជាគោលការណ៍ ច្បាប់បង្កើតឡើងដើម្បីជាប្រយោជន៍មនុស្សទូទៅនៅក្នុងសង្គម ហើយតែងតែមានការពាក់ព័ន្ធនឹងពលរដ្ឋ ដូច្នេះពលរដ្ឋម្ចាស់ឆ្នោតដែលរស់នៅក្នុងសង្គមក៏គួរតែបានទទួលព័ត៌មានឲ្យបានគ្រប់គ្រាន់ផងដែរ ។

រដ្ឋាភិបាលគួរតែបើកចំហ និងលើកទឹកចិត្តឲ្យមានការចូលរួមយ៉ាងពិតប្រាកដ និងផ្សារភ្ជាប់ការពិភាក្សាជាមួយនឹងប្រជាពលរដ្ឋ តាមរយៈអង្គការសង្គមស៊ីវិល និងគណបក្សនយោបាយផ្សេងៗ ទៅគ្រប់ឆាកនៃដំណើរការតាក់តែងច្បាប់សំខាន់ៗ ឬយ៉ាងហោចណាស់ការតាក់តែងសេចក្តីព្រាងច្បាប់បឋម ជាមួយនឹងការគាំទ្រផ្នែកព័ត៌មានដ៏ត្រឹមត្រូវនឹងគ្រប់ជ្រុងជ្រោយឲ្យស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា៕

**អ្នកឃ្លាំមើល**

# ពានរង្វាន់ប្រចាំឆ្នាំ ២០០៩ សម្រាប់លេខារាជធានី ខេត្តគណៈកម្មាធិការខុមហ្វ្រែល

តាំងពីឆ្នាំ២០០៥មក គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) តែងតែរៀបចំការវាយតម្លៃរកចំណាត់ថ្នាក់លេខាខុមហ្វ្រែល រាជធានី ខេត្ត ជារៀងរាល់ឆ្នាំ ដើម្បីសម្តែងការទទួលស្គាល់នូវកិច្ចខិតខំប្រឹងប្រែង និងគុណវឌ្ឍន៍ផ្ទាល់ខ្លួនរបស់លេខាខុមហ្វ្រែលទាំង ២៤ រាជធានី ខេត្ត។ ដោយឡែកសម្រាប់ឆ្នាំ២០០៩នេះ លទ្ធផលដែលទទួលបានមានលក្ខណៈពិសេសជាងបណ្តាឆ្នាំកន្លងមក ព្រោះខុមហ្វ្រែល រកបានចំណាត់ថ្នាក់លេខ២ស្មួន ដល់ទៅ ៤ រូប។

ដោយយោងតាមការវាយតម្លៃពីក្រុមវាយតម្លៃនៃគណៈកម្មាធិការខុមហ្វ្រែល បានផ្តល់ពិន្ទុ និងចំណាត់ថ្នាក់ដោយផ្តោតលើលក្ខណៈវិនិច្ឆ័យចំនួន ៥ យ៉ាងដូចជា ៖ (១). ការផ្តួចផ្តើមគំនិត និងការច្នៃប្រឌិត (២). ភារកិច្ច និងការសម្របសម្រួលក្នុងក្រុម (៣). វិន័យរដ្ឋបាល និងក្រមសីលធម៌ (៤). ការតាំងចិត្ត និងប្តេជ្ញាចិត្ត និង (៥). ជំនាញ និងគុណភាពការងារ បានសម្រេចធ្វើការជ្រើសរើសយកអ្នកមានស្នាដៃការងារល្អចំនួន ៥ រូប ដែលមានសមាសភាពដូចតទៅ ៖

☝**ចំណាត់ថ្នាក់លេខមួយ** ៖



លោក. **លាត ម៉ុនលាង**
ជាលេខាខេត្តកំពង់ឆ្នាំង

បានទទួលជ័យលាភី ចំណាត់ថ្នាក់លេខមួយ ៣ ឆ្នាំជាប់គ្នាៗមកហើយ។ លោក **ម៉ុនលាង** មានអាយុ ៣៩ឆ្នាំ បានបម្រើការងារជាលេខាខុមហ្វ្រែលតាំងពីឆ្នាំ២០០១។ លោក ត្រូវបានក្រុមវាយតម្លៃដែលមានសមាសភាពចំរុះទទួលស្គាល់ថា ជាលេខាមួយរូបដែលមានភាពឆ្នើមផ្តាច់គេលើកិច្ចសម្របសម្រួល វិន័យរដ្ឋបាល ក្រមសីលធម៌ ការប្តេជ្ញាចិត្ត គំនិតផ្តួចផ្តើម និងគុណភាពការងារ។ លោក **ម៉ុនលាង** បានបង្ហើបឲ្យដឹងពីគន្លឹះផ្ទាល់ខ្លួនដែលនាំឲ្យរូបលោកអាច រក្សាចំណាត់ថ្នាក់លេខមួយថា ៖ "ខ្ញុំមានលទ្ធផលដូចនេះដោយសារ ខ្ញុំមានការព្យាយាម ខ្ញុំធ្វើការពេញម៉ោងទៀងពេល និងរក្សាបាននូវទំនាក់ទំនងល្អជាមួយនឹងអាជ្ញាធរពាក់ព័ន្ធ"។

✌**ចំណាត់ថ្នាក់លេខ ២** ៖



អ្នកស្រី **នេត គឹមចន**
លេខាខេត្តស្វាយរៀង

បានបម្រើការងារនៅក្នុងខុមហ្វ្រែលតាំងពីឆ្នាំ២០០១។

លោកស្រី **គឹម ចន** មានអាយុ៥៣ឆ្នាំ ហើយនាំមុខលើផ្នែកសម្របសម្រួល វិន័យរដ្ឋបាល និងការតាំងចិត្ត។ លោកស្រី មានឆន្ទៈខ្ពស់ក្នុងការងារ ហើយបានលាតត្រដាងពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនចំពោះការងារជាលេខាៈ "ខ្ញុំចូលធ្វើការងារជាមួយនឹងខុមហ្វ្រែលដើម្បីអាចចុះទៅសង្កេតរាល់សកម្មភាពការងាររបស់ក្រុមប្រឹក្សាឃុំ និងអ្នកតំណាងរាស្ត្រ..." ទោះបីជាយ៉ាងនេះក្តី អ្នកស្រី ហាក់មានការបារម្ភអំពីអនាគតក្នុងការរក្សាមុខងារនេះ ដែលត្រូវការកម្លាំងកាយ និងកម្លាំងប្រាជ្ញា ៖ "ប្រសិនបើសុខភាព ឬកម្លាំងរបស់ខ្ញុំនៅតែអំណោយផល ខ្ញុំនឹងនៅតែតស៊ូជាមួយនឹងខុមហ្វ្រែលជារៀងរហូត"

**✌ចំណាត់ថ្នាក់លេខ ២ ស្មួន** ៖



លោក. **ជួន តិនដារ៉ា**
លេខាខេត្តរតនគីរី
អាយុ ៣៥ ឆ្នាំ

បានបម្រើការងារជាមួយនឹងខុមហ្វ្រែលតាំងពីឆ្នាំ២០០៣ ហើយនៅរក្សាបានចំណាត់ថ្នាក់ខ្ពស់ផ្នែកវិន័យរដ្ឋបាល គំនិតផ្តួចផ្តើម គុណភាពការងារ និងកិច្ចសម្របសម្រួល។ លោកមានចំណាប់អារម្មណ៍ថា ៖ "សម្រាប់ខ្ញុំ មានការសប្បាយចិត្តដែលទទួលបានចំណាត់ថ្នាក់លេខ២ តែទោះបីជាយ៉ាងណាការងារនៅតែត្រូវបំពេញឲ្យល្អថែមទៀត ព្រោះការងារដែលយើងត្រូវបំពេញជាផ្នែក ជាច្រមុះ របស់ខុមហ្វ្រែល "

**✌ចំណាត់ថ្នាក់លេខ ២ ស្មួន** ៖



លោក. **ចៅ វុទ្ធី**
លេខាខេត្តឧត្តរមានជ័យ
អាយុ ៤០ ឆ្នាំ

បានចូលបម្រើការងារជាមួយនឹងខុមហ្វ្រែលតាំងពីឆ្នាំ២០០១។ លោកឈ្នះចិត្តក្រុមវាយតម្លៃទទួលស្គាល់បានជាលេខាមួយរូបដែលមានភាពលេចធ្លោលើ គំនិតផ្តួចផ្តើម កិច្ចសម្របសម្រួល វិន័យរដ្ឋបាល និងគុណភាពការងារ។ លោកបានរៀបរាប់ពីឧបសគ្គមួយចំនួនដែលបានជួបក្នុងពេលបំពេញការងារ និងការប្តេជ្ញាចិត្ត ៖ "មានជួបការលំបាកដែរ ដោយសារអង្គការខុមហ្វ្រែល មិនមានថវិកាសម្រាប់ចំណាយរដ្ឋបាល និងចុះទៅតាមមូលដ្ឋាន តែទោះបីជាយ៉ាងណា យើងនៅតែខំប្រឹងប្រែងដើម្បីឲ្យការងារបានសម្រេច ពិសេសត្រូវបំពេញតាមការដាក់ចុះពីស្នាក់ការកណ្តាលឲ្យបានត្រឹមត្រូវ"

**✌ចំណាត់ថ្នាក់លេខ ២ ស្មួន** ៖



កញ្ញា **រ៉េន ម៉ាឌីណា**
លេខាខេត្តកំពង់ធំ
អាយុ ២៧ ឆ្នាំ

បានចូលបម្រើការងារជាលេខាខុមហ្វ្រែលតាំងពីឆ្នាំ២០០៤។ កញ្ញា មានភាពលេចធ្លោផ្នែកគំនិតផ្តួចផ្តើម កិច្ចសម្របសម្រួលវិន័យរដ្ឋបាល និងការប្តេជ្ញាចិត្ត។ កញ្ញា ម៉ាឌីណា បានសម្តែងនូវអំណរគុណចំពោះខុមហ្វ្រែល ដែលបានផ្តល់ឱកាសការងារ ហើយបានបំពេញតាមការស្នើសុំរបស់កញ្ញាក្នុងការបណ្តុះបណ្តាល និងឧបត្ថម្ភថវិកាសិក្សាដើម្បីពង្រឹងសមត្ថភាពចំពោះការប្រើប្រាស់កុំព្យូទ័រ ភាសាអង់គ្លេស រៀបចំវេទិកាសាធារណៈ ការសម្របសម្រួល អង្កេតការណ៍បោះឆ្នោត... ដែលនាំឲ្យរូបកញ្ញាមានឱកាសដូចពេលនេះ។ កញ្ញា បានបង្ហើបឲ្យដឹងពីឆន្ទៈ និងមហិច្ឆតានាពេលអនាគតៈ "ខ្ញុំនឹងខិតខំជួយការងារខុមហ្វ្រែលឲ្យពេញទំហឹង ហើយក៏អភិវឌ្ឍជំនាញ និងចំណេះដឹងរបស់ខ្លួនថែមទៀត ដោយសង្ឃឹមថា នាពេលអនាគត នាងខ្ញុំអាចនឹងក្លាយជាអ្នកសម្របសម្រួលខុមហ្វ្រែលក្នុងការតាមដានការបោះឆ្នោត"។

ខុមហ្វ្រែលនៅតែបន្តវាយតម្លៃរកចំណាត់ថ្នាក់គំរូ និងផ្តល់ការលើកទឹកចិត្តចំពោះបុគ្គលិកឆ្នើមជារៀងរាល់ឆ្នាំ ហើយលទ្ធផលទាំងនេះគឺបានមកពីឆន្ទៈ កិច្ចខិតខំប្រឹងប្រែង និងស្នាដៃដែលសម្រេចបានរបស់បុគ្គលខ្លួនឯងផ្ទាល់៕

# ការបោះឆ្នោតនៅរដ្ឋហ្លរីដា Florida នៃសហរដ្ឋអាមេរិក

រដ្ឋ **ហ្វ្លរីដា** (Florida)ជារដ្ឋគំរូខាងរៀបចំការបោះឆ្នោត ដែលការបោះឆ្នោតជាមួយនឹង ឧបករណ៍ទំនើប និង គំនិតច្នៃប្រឌិតដែលធ្វើយ៉ាងណាដើម្បីឱ្យលទ្ធផលនៃការបោះឆ្នោតទទួលស្គាល់ដោយប្រជាជន។ ប្រជាជនមាន សុខុមាលភាព និងសុវត្ថិភាពក្នុងការទៅបោះឆ្នោត និងត្រូវបានប្រជាពលរដ្ឋផ្តល់នូវ ទំនុកចិត្តលើការរៀបចំរបស់ មជ្ឈមណ្ឌលបោះឆ្នោត។ ដោយប្រទេសអាមេរិកជាប្រទេសប្រធានាធិបតីនិយម ដូចនេះការបោះឆ្នោតចែកជា២ គឺ បោះឆ្នោតជ្រើសរើសសភា និងប្រធានាធិបតី (រាជរដ្ឋាភិបាល)។ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងប្រទេសដែលមាន ដល់ទៅ៥០រដ្ឋនោះ និង ដើម្បីឱ្យអំណាចមិនប្រមូលផ្តុំនោះ ប្រទេសនេះចែកជា ៣ ឋានានុក្រម គឺថ្នាក់លើ (Federal level) ថ្នាក់រដ្ឋ (State level) ថ្នាក់ក្រោម (Local level) ដូចនេះការបោះឆ្នោតមានគ្រប់ថ្នាក់។ មានន័យថាថ្នាក់នីមួយៗគេមាន រដ្ឋសភា រដ្ឋាភិបាល និង តុលាការ ដែលទទួលការសំលេងគាំទ្រពីការបោះឆ្នោតរបស់ប្រជាពលរដ្ឋ។ នៅក្នុងប្រទេសអាមេរិកមាន ៥០រដ្ឋ ដែលរដ្ឋនីមួយៗគេមានទីក្រុងជាច្រើន ទីក្រុងនីមួយៗមានសហគមន៍ ដែលសុទ្ធទទួលការគាំទ្រ និង ឧបត្ថម្ភពីរដ្ឋាភិបាល និងអង្គការក្នុងស្រុកតូចធំ។ និយាយត្រឡប់មកវិញ មានន័យថា សហរដ្ឋអាមេរិក មានរដ្ឋសភាជាតិដែលជាសមាជិកសភាជាតំណាងរដ្ឋនីមួយៗ ហើយចំនួនគឺកំណត់តាមចំនួនរបស់ប្រជាជនតាមរដ្ឋ។ សភាថ្នាក់កណ្តាល(សភារបស់រដ្ឋនីមួយ)ដែល សមាជិកមកពីសភាក្រុងដែលមានទីតាំងនៅក្នុងរាជធានីនរដ្ឋនោះ ក្រុមប្រឹក្សាក្រុងដែលជាសភាថ្នាក់ក្រោមដែលសមាជិកជាតំណាងសង្កាត់នីមួយៗនៅក្នុងទីក្រុង។ ប្រជាជនតែងចូលរួម និងលើកពីការកង្វល់ បញ្ហាតាមរយៈការប្រជុំរបស់សភាក្រុង។


វិមានរដ្ឋាភិបាលសហរដ្ឋអាមេរិក

## ការបោះឆ្នោតនៅរដ្ឋហ្វ្លរីដា

- ការបោះឆ្នោតមាន ៣ប្រភេទគឺៈ
  - តាមរយៈការផ្ញើមែល គឺត្រូវមកយកសំបុត្រនៅមជ្ឈមណ្ឌលបោះឆ្នោតសិន បន្ទាប់ពីសំរេច ជ្រើស រើស ហើយ និងចុះហត្ថលេខារួចផ្ញើត្រឡប់មកមជ្ឈមណ្ឌលរៀបចំការបោះឆ្នោតវិញ។
  - ការបោះឆ្នោត២សប្តាហ៍ទុកជាមុន អាចបោះនៅតាមបណ្ណាល័យ ទីសាធារណៈ ព្រះវិហារ តាមទីក្រុង ចំនួន ៥០ កន្លែង។
  - និង បោះនៅថ្ងៃបោះឆ្នោតតែម្តង ដែលមាន ២៧២ ទូ។

- ការចុះឈ្មោះត្រូវបោះឆ្នោតត្រូវទៅចុះមុនរយៈពេល២៩ថ្ងៃមុនថ្ងៃបោះឆ្នោត។ ប្រជាជនតែងទទួលការបង្រៀន ហ្វឹកហាត់ជាមុន ដើម្បីងាយស្រួល និងយល់ពីរបៀបនៃការបោះឆ្នោត។ ការចុះឈ្មោះ ឯកសារដែល ប្រជាពលរដ្ឋ ត្រូវមាននោះគឺតែមួយគត់គឺប័ណ្ណបើកបរ ព្រោះប្រជាពលរដ្ឋ ដែលអាចបោះឆ្នោតបានគឺមានអាយុស្មើនឹង១៨ឆ្នាំ ដែលតំរូវឱ្យមានប័ណ្ណបើកបរ ហើយដែលនៅក្នុងប័ណ្ណបើកបរ នេះបានស្រង់រាល់ទិន្នន័យរបស់សាមីខ្លួនរួចជា

ស្រេច ដោយគ្រាន់តែឆូតកាតនេះទៅនឹងម៉ាស៊ីនជាការស្រេច។ អាចចុះឈ្មោះបោះតាមរយៈការផ្ញើមែលដែលគ្រាន់តែភ្ជាប់មក ជាមួយនូវឯកសារពាក់ពន្ធដែលជាតំរូវការឱ្យបំពេញ។

- លក្ខខណ្ឌនៃការចុះឈ្មោះគឺ
  - ត្រូវមានសញ្ជាតិអាមេរិក
  - ជាប្រជាពលរដ្ឋរស់នៅរដ្ឋ ហ្វ្លរីដា
  - មិនមានបញ្ហាខួរក្បាល
  - មិនមានឈ្មោះក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ
  - មានប័ណ្ណបើកបរ
  - បំពេញទំរង់បែបបទខ្លះៗ

- ចំពោះជំលោះដែលប៉ះពារគ្នានៅក្នុងពេលឃោសនាគឺមិនដែលបានប្តឹងទៅតុលាការទេ គឺដោះស្រាយតាមការសុំទោស គ្នាតាមរយៈលិខិតសុំទោសតែប៉ុណ្ណោះ។
- គណបក្សមាន២ប្រភេទ គណបក្សសម្លេងភាគច្រើន មានគណបក្សសាធារណរដ្ឋ និង គណបក្សប្រជាធិតេយ្យ និងចំណែកគណបក្សសំលេងភាគតិចមានសំលេងតិចជាង ៥%នៃការចុះឈ្មោះ។
- ថ្ងៃបោះឆ្នោតគឺគេចាប់ពីម៉ោង ៧ព្រឹក-៧ល្ងាច មាន ២៣២ មណ្ឌលបោះឆ្នោត បន្ទាប់មកចាប់ផ្តើម រាប់សន្លឹកឆ្នោតយកតែម្តងដោយមានទិន្នន័យទាំងអស់ត្រូវបានបញ្ចូលទៅក្នុង ៧០ ម៉ូដឹម និង មេម៉ូរីកាត ហើយលទ្ធផលនឹងធ្វើ សន្និសីទកាសែតនៅពេលយប់ភ្លាមៗជាមួយនឹងបេក្ខជន និងអ្នកកាសែត។ ដោយប៉ូលីស ជាអ្នកដែលប្រជាជនអាមេរិចទាំងផ្តល់ជំនឿចិត្ត ទើបប្រជាពលរដ្ឋស្នើឱ្យមានប៉ូលីសនៅក្រៅមណ្ឌលបោះឆ្នោត គឺដើម្បីការពារសុវត្ថិភាព ប្រជាពលរដ្ឋអាមេរិកមានភាពកក់ក្តៅក្នុងការបោះឆ្នោត។
- ហិបឆ្នោតគឺមានលក្ខណៈពិសេសត្រង់រាប់សន្លឹកឆ្នោតដោយបង្ហាញទិន្នន័យភ្លាមៗ ហើយលក្ខណៈពិសេសមួយទៀត គឺហិបនេះមិនទទួលចំពោះសន្លឹកឆ្នោតដែលគូសជ្រើសរើស ២ជំរើស និងមិនគូសជ្រើសរើសសោះ។ ចំពោះម៉ាស៊ីន រៀបសន្លឹកឆ្នោតដែលធ្វើជាសំបុត្រក៏មិនទទួលយកសំបុត្រណាដែលមិនចុះហត្ថលេខា ឬហត្ថលេខាមិនដូចក្នុងប័ណ្ណបើកបរ។



## បទពិសោធន៍ដែលបានទទួល

- សង្កេតឃើញថាប្រជាពលរដ្ឋទាំងអស់ចូលរួមរាល់ពេលប្រជុំសភាដើម្បីលើកជាបញ្ហាសុំឱ្យសភាក្រុងជួយ ដោះស្រាយ សំរាប់សភាថ្នាក់រដ្ឋមានការចូលរួមរបស់ប្រជាជនក្នុងការអង្កេតតាមដានពីដំណើរការប្រជុំ របស់ សភាតើតំណាងរាស្ត្រគាត់បានលើកនូវបញ្ហាដែលពួកគាត់ស្នើឱ្យតំណាងគាត់ជួយឬអត់ ដែលជាគំរូដ៏ល្អសំរាប់

ប្រជាជនកម្ពុជា ក្នុងចូលរួមតាមដាន អង្កេតពីការធ្វើការ និងការជួយអន្តរាគមន៍របស់តំណាងរបស់ខ្លួន ដែលបានបោះឆ្នោតឱ្យ។ មិនចាំបាច់តែតំណាងរដ្ឋជួយអន្តរាគមន៍ទេ តំណាងក្រុងក៏អាចជួយបានដែរ។

- ប្រធានមជ្ឈមណ្ឌលបោះឆ្នោតប្រកាន់គោលជំហរថា ការបោះឆ្នោតគឺធ្វើយ៉ាងណាផ្តល់ទំនុកចិត្ត ជាសុខភាព សុវត្ថិភាព ផ្សព្វផ្សាយពត៌មានឱ្យបានទូលំទូលាយ និងការបង្ហាត់បង្រៀនដល់ប្រជាពលរដ្ឋ ដើម្បីឱ្យពួកគាត់យល់ថាលទ្ធផលនៃការបោះឆ្នោតត្រូវបានពួកគាត់ទទួលស្គាល់។
- ទីតាំងរបស់សភានីមួយៗគ្រប់ជាន់ថ្នាក់ បានបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋឱ្យបានស្គាល់ និងចូលរួម ដូចជាទីតាំងធ្វើការរបស់សភា និងរដ្ឋាភិបាលនៅ រដ្ឋកាលីហ្វ័រញ៉ា នៅរាជធានីសាកក្រាមិនតូ បានបើក ជាសាធារណៈចំពោះភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ និងអ្នកទស្សនកិច្ចសិក្សាដោយមានអ្នកមគ្គុទេសក៏ ចាំជួយបង្ហាញ។
- ចំពោះជំលោះដែលកើតមាននៅពេលឃោសនា គួរតែយកគំរូតាមប្រជាជននៅរដ្ឋនេះ ព្រោះមិនគួរបង្កឱ្យមានការប្តឹងផ្តល់គ្នាដល់តុលាការទេ ឬបង្កមានការបង្ករបួសស្នាមទេត្រូវមានការយោគយល់គ្នា និងសំរុះសំរួលគ្នា ព្រោះមិនមានការចំណេញទាំងសងខាងបើប្តឹងទៅតុលាការ។

**ដោយកញ្ញា ម៉ា លីន**

# របាយការណ៍សង្ខេបសភាតំណាងរាស្ត្រ

កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ

ពីខែ តុលា ដល់ ខែវិច្ឆិកា ២០០៩

## រដ្ឋសភា

- **០១-១៦ តុលា**: រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សាលើច្បាប់ចំនួន៣៖
    - ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីក្រមព្រហ្មទណ្ឌ
    - ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី
    - ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម
- **១៤ តុលា:** តុលាការសាលាឧទ្ធរណ៍ប្រកាសតម្កល់បណ្តឹងរបស់អ្នកតំណាងរាស្ត្រ មូរ សុខហួរ ប្រឆាំងនឹងសម្តេច ហ៊ុន សែន ពីបទបរិហារកេរ្តិ៍។ អ្នកតំណាងរាស្ត្ររូបនេះធ្លាប់ដាក់បណ្តឹងទៅសាលា ដំបូងភ្នំពេញ ហើយតែត្រូវបានសាលាដំបូង តម្កល់ព្រោះចោទថាភស្តុតាងដាក់បន្ទុកមិនគ្រប់គ្រាន់។ ចំណែកបណ្តឹងរបស់សម្តេច ហ៊ុន សែន ត្រូវបានតុលាការសំរេចដោយតំរូវឱ្យអ្នកតំណាងរាស្ត្រ មូរ សុខហួរ បង់ពិន័យ ៨០០០ដុល្លារអាមេរិក។



- **១៦ តុលា:** កម្មករ កម្មការិនីក្រុមហ៊ុនតាកហ្វាតចំនួនជិត១០០០នាក់នាំគ្នាជួបជុំគ្នានៅមុខវិមានរដ្ឋសភា ដើម្បីសុំឱ្យអ្នកតំណាងរាស្ត្រជួយអន្តរាគមន៍ចំពោះក្រុមហ៊ុនដែលមិនបើកប្រាក់ខែឱ្យកម្មករ និងបើកមិនគ្រប់ចំនួន។ ពេលនោះ មានតែអ្នកតំណាងរាស្ត្រ **មូរ សុខហួរ** មណ្ឌលកំពត និងតំណាងរាស្ត្រ **ហួរ ថាន់** មណ្ឌលភ្នំពេញ បានចេញមកស្វាគមន៍។ ចំណែកអ្នកតំណាងរាស្ត្រ **ឃួន សុដារី** ជាប្រធានគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា បានជួយទទួលពាក្យបណ្ដឹង ពីតំណាងកម្មករ និងរៀបចំដើម្បីអន្តរាគមន៍បន្ត។
- **១៧ តុលា:** អ្នកតំណាងរាស្ត្រ **សម រង្ស៊ី** ចូលរួមកិច្ចស្ដីពីសិទ្ធិមនុស្សនៅសម័យប្រជុំសភាអឺរ៉ុប។
- **៣០ តុលា និង ០១/០២ វិច្ឆិកា:** រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សាលើច្បាប់ស្ដីពីការពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងថវិកាជាតិ ២០១០។
- **១៦ វិច្ឆិកា:** រដ្ឋសភាប្រជុំវិសាមញ្ញជាសំងាត់ដើម្បីដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ សមរង្ស៊ី មណ្ឌល កំពង់ចាម ដែលបានប្រព្រឹត្តអំពើដកបំផ្លាញតម្រុយបង្គោលព្រំដែនកម្ពុជា វៀតណាម និងញុះញង់ឱ្យ ប្រព្រឹត្តបទល្មើសឧក្រិដ្ឋ និងមជ្ឈឹមដោយពុំបានសំរេចផល នៅស្រុកចន្ទ្រា ខេត្តស្វាយរៀងកាលពី **ថ្ងៃទី ២៥ តុលា។**
- **១៦ វិច្ឆិកា:** អ្នកតំណាងរាស្ត្រ គណបក្សសមរង្ស៊ីបានធ្វើសន្និសីទនៅមុខរដ្ឋសភាពីការដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ សម រង្ស៊ី ហើយបានធ្វើការដង្ហែពីរដ្ឋសភាកាត់តាមសួនច្បារវិមានឯករាជ្យ ហើយវង់ទៅទីស្នាក់ការ គណបក្សសមរង្ស៊ី។
- **២៣ វិច្ឆិកា:** ថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិមាន សម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និង សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានទូលថ្វាយព្រះមហាវីរក្សត្រសម្ដេចព្រះ នរោត្តម **សីហនុ** ជាព្រះវររាជបិតាជាតិខ្មែរ នៅក្នុងលិខិតមួយ ដែលចុះហត្ថលេខា ដោយសម្ដេចទាំង៣កាលពីថ្ងៃទី១៦វិច្ឆិកាឆ្នាំ២០០៩ ទាក់ទងទៅនឹងលិខិតរបស់លោក សមរង្ស៊ី ទូលថ្វាយព្រះមហាវីរក្សត្រកន្លងទៅស្ដីពីការដកបង្គោលព្រំដែននៅថ្ងៃទី៧វិច្ឆិកា២០០៩។
- **១៤ ធ្នូ:** អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីចំនួន ២១រូប បានចុះទៅពិនិត្យបង្គោលព្រំដែនកម្ពុជា វៀតណាម ស្រុកចន្ទ្រា ក្នុងខេត្តស្វាយរៀង ទៅពិនិត្យបង្គោលតម្រុយព្រំដែនលេខ ១៨៥ ដែលលោក សមរង្ស៊ី បានដឹកនាំអ្នកភូមិដកបង្គោល ត្រូវកម្លាំងអាជ្ញាធរ ប៉ូលីស ពី២០ទៅ៣០ នាក់ ស្ទាក់ផ្លូវមិនឱ្យចូលបន្ទាប់មក មានការរុញទៅរុញមករវាង ប្រជាពលរដ្ឋ តំណាងរាស្ត្រនិង ប៉ូលីស ដែលអាចឱ្យអ្នកតំណាងរាស្ត្រ និង ប្រជាជនអាចចូលទៅមើលបង្គោលបាន ដោយមិនបានបង្ករបួសស្នាមដល់ភាគីណាទេ។
- **២៤ ធ្នូ:** ឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន បានអញ្ជើញមករដ្ឋសភាដើម្បីបំភ្លឺលើសំនួររបស់អ្នកតំណាងរាស្ត្រ **សុន ឆ័យ** មណ្ឌលភ្នំពេញ ដែលសុំឱ្យរាជរដ្ឋាភិបាលផ្ដល់ឯកសារ ស្ដីពីកិច្ចព្រមព្រៀង និងនិតីវិធីនៃការអនុវត្តការងារបោះបង្គោលព្រំដែនកម្ពុជា វៀតណាម និងការអញ្ជើញអ្នក ឯកទេសខាងផ្នែកព្រំដែន នៅពន្យល់ពីកិច្ចការបោះបង្គោលព្រំដែននៅរដ្ឋសភាកាលពី ថ្ងៃទី ២៦ វិច្ឆិកា តែត្រូវបានអ្នកតំណាងរាស្ត្រ **សុន ឆ័យ** មានប្រសាសន៍ថាការឆ្លើយមិនសូវត្រូវនឹងអ្វីដែលគាត់បានសួរ ។
- **២៨ ធ្នូ:** អ្នកតំណាងរាស្ត្រ សម រង្ស៊ី ត្រូវតុលាការកោះហៅឱ្យចូលមកបំភ្លឺនៅតុលាការខេត្តស្វាយរៀងដើម្បីសាកសួរអំពីការដកបង្គោលព្រំដែនតែមិនមានវត្តមានរបស់អ្នកតំណាងរាស្ត្ររូបនេះទេព្រោះគាត់កំពុងនៅបរទេស។

## *ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក្នុងរយៈពេល៣ខែវិស្សមកាល(តុលា-ធ្នូ)*

នៅក្នុងខែ តុលា វិច្ឆិកា និងធ្នូនេះ ឆ្នាំ២០០៩ ដែលជាពេលបញ្ចប់វិស្សមកាលរបស់រដ្ឋសភាសម្រាប់ តំណាងរាស្ត្រ ចុះទៅជួបប្រជាជន និងក៏ជាដើមសម័យប្រជុំពេញអង្គលើកទី៣ នាំឱ្យការជួបសួរសុខទុក្ខមានការថយចុះតិចជាងខែមុនៗច្រើន មានអ្នកតំណាងរាស្ត្រចំនួន ៥៤ រូប មកពីគណបក្ស ជាប់ឆ្នោតតែ៤បានចុះ មូលដ្ឋាន បានចំនួន ១៥៩ លើក។ នេះបើតាមពត៌មានដែលខុមហ្វ្រែល ទទួលបាន។

អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចំនួនយ៉ាងតិច ៤០ រូប ( ស្មើនឹង ៤៥% នៃតំណាងរាស្ត្រសរុប ៩០រូប ) បានចុះមូលដ្ឋានចំនួន១០៥ លើក ឬជាមធ្យម អ្នកតំណាងរាស្ត្រមួយរូប ចុះមូលដ្ឋានបានចំនួន៥លើក។ ចំណែកតំណាងរាស្ត្រ គណបក្សសិទ្ធិមនុស្សដែលមានតែ ៣រូប ចុះមូលដ្ឋានទាំងអស់ ស្មើនឹង ១០០% បានចំនួន ២៨លើក ឬមធ្យមអ្នកតំណាងរាស្ត្រ មួយរូបចុះបាន ១០លើក។ ខណៈដែលតំណាងរាស្ត្រគណបក្ស សមរង្ស៊ីបាន ចុះមូលដ្ឋាន ចំនួន ១០រូប ( ស្មើនឹង ៣៩%នៃ អ្នកតំណាងរាស្ត្រ គណបក្ស នេះសរុប ២៦នាក់ ) បានចុះមូលដ្ឋានសរុបតែ ២៤លើក មានន័យថា ជាមធ្យម អ្នកតំណាងរាស្ត្រ គណបក្សនេះ មួយរូបចុះមូលដ្ឋាន បាន ៣លើក។ តំណាងរាស្ត្រមកពី គណបក្សហ៊្វុនស៊ិនប៉ិច ១ រូប បានចុះចំនួន ២ លើក ( ៥០%ស្មើនឹង នៃអ្នកតំណាងរាស្ត្រគណបក្សនេះសរុប ២រូប ) និង គណបក្សជាតិនិយម( អតីតគណបក្សនរោត្តមរណឫទ្ធិ ) ខាងខុមហ្វ្រែល មិនបានទទួលពត៌មានពីការចុះមូលដ្ឋានទេ។

ចំនួនលើកនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្រ

ពង្រឹងផ្ទៃក្នុង គណបក្ស ៣០%(ស្មើនឹង ៤៦ លើក)។ ខណៈដែលការចុះអន្តរាគមន៍ មានតែ ១% (១លើក) និងការអមដំណើរថ្នាក់ដឹកនាំ ស្មើនឹង ៦%(៩លើក)។ចំណែកការចូលរួមក្នុង វេទិកាសាធារណៈ មានតិចតួចស្មើនឹង ១លើក។

- ការសាកសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធគម្រោងនានា ត្រូវបានធ្វើឡើងដោយតំណាងរាស្ត្រមកពី ៤ គណបក្សដែលគណបក្សប្រជាជនកម្ពុជាឈានមុខគេ ចំនួន ៨៣លើក លើគណបក្សសមរង្ស៊ីដែលមានសរុប ១៥លើក គណបក្សសិទ្ធិមនុស្សចំនួន ២លើក និង គណបក្សហ៊្វុនស៊ិនប៉ិចមានតែ ១លើក។ នៅថ្ងៃទី ៣០ ខែវិច្ឆិកា អ្នកតំណាងរាស្ត្រ **ទ្រី ឈាងហួត** មណ្ឌលបន្ទាយមានជ័យ គណបក្សប្រជាជនកម្ពុជា បានចុះសួរសុខទុក្ខប្រជាជននៅភូមិឈូកឃុំពន្លៃស្រុកភ្នំស្រុកចំនួន៤១គ្រួសារ ដែលជួបបញ្ហាស្រូវលិចទឹកអស់ និងចែកអំណោយសារុងចំនួន ១ អង្ករ ២៥គីឡូក្រាម មី១០កញ្ចប់ ទឹកស៊ីអ៊ីវ ៦០ដប អំបិល២គីឡូក្រាម ក្នុង១គ្រួសារ និងចែកថវិកាដល់លោកគ្រូបង្រៀន២នាក់ ម្នាក់ ៤០០០០រៀល មេភូមិ២នាក់ ៤០០០០រៀល និងសិស្ស៥៦នាក់ ៦០០០០រៀល។
- ការចុះពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្ស តំណាងរាស្ត្រមកពីគណបក្ស៤បានចុះពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្សរបស់ខ្លួនសរុប ចំនួន ២៤លើក ដែល គណបក្សសិទ្ធិមនុស្សបានចុះ ២៤លើក គណបក្សប្រជាជនកម្ពុជា ១៤លើក និងគណបក្សសមរង្ស៊ី ៧លើក ផងដែរ ដូចជាអ្នកតំណាងរាស្ត្រ គណបក្សសិទ្ធិមនុស្ស **កឹម សុខា** បានចូលរួមប្រជុំ សំណេះសំណាល និងសួរសុខទុក្ខសកម្មជន និងប្រជាពលរដ្ឋ ១៣គ្រួសារដែលគាំទ្រគណបក្ស អ្នកចូលរួមមានដែលមានចំនួន ១២៤នាក់ នៅថ្ងៃទី ១២ ខែវិច្ឆិកា។ អ្នកតំណាងរាស្ត្រ **នុត រំដួល** មណ្ឌលកំពង់ស្ពឺរបស់គណបក្សសមរង្ស៊ី បានចូលរួមក្នុងការពង្រឹងសកម្មជនរបស់គណបក្សខេត្តដើម្បីត្រៀមសង្កេតមើលការចុះឈ្មោះបោះឆ្នោត ២០០៩ នៅស្នាក់ការគណបក្សខេត្ត នៅថ្ងៃទី២៦ កញ្ញា ២០០៩។
- ការអន្តរាគមន៍ និង ដោះស្រាយបញ្ហានានា មានតែតំណាងរាស្ត្រប្រជាជនកម្ពុជា និងគណបក្សសមរង្ស៊ីទេ ដែលបានចុះមូលដ្ឋាន ដើម្បីអន្តរាគមន៍ និងដោះស្រាយបញ្ហាជូនប្រជាជន ចំនួនគេ ១លើក ដូចគ្នា ដែលក្នុងនោះរួមមាន អ្នកតំណាងរាស្ត្រ **នុត រំដួល** មកពីគណបក្សសមរង្ស៊ី មណ្ឌលកំពង់ស្ពឺ ជួយដោះស្រាយបញ្ហាទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋ និង ប្រជាពលរដ្ឋ ២គ្រួសាររឿងដីធ្លី ដោយព្រំដីមិនត្រូវគ្នា នៅឃុំទួលអំពិល ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០០៩។ និង អ្នកតំណាងរាស្ត្រ **និន សាផុន** មណ្ឌលតាកែវ គណបក្សប្រជាជនកម្ពុជា បានអញ្ជើញចុះអន្តរាគមន៍ ជួយបូមទឹកដាក់ស្រូវជូន ប្រជាពលរដ្ឋនៅ ភូមិពេជសារ និងភូមិពោន ឃុំពេជសារ ស្រុកអង្គោត ហើយលោកជំទាវបាន ឧបត្ថម្ភប្រេងម៉ាស៊ូត ៣០០លីត្រដល់ប្រជាពលរដ្ឋ សំរាប់បូមទឹកបាក់ស្រូវ នៅថ្ងៃទី២៨ ខែវិច្ឆិកា ២០០៩។
- ការចុះអមដំណើរថ្នាក់ដឹកនាំ មានដល់ទៅ ៩លើកដែលគណបក្សប្រជាជនកម្ពុជាមានដល់ទៅ ៧ដង និងគណបក្សសិទ្ធិមនុស្សមាន២លើក ដូចជាអ្នកតំណាងរាស្ត្រ ឯកឧត្តម **ញឹម វណ្ណដា** អញ្ជើញចុះអមដំណើរ ឯកឧត្តម **ស ខេង** ចូលរួមប្រជុំបូកសរុបការងារយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាស្រុក ខេត្ត នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជាខេត្ត ភ្ញៀវចូលរួមប្រហែល៦០០នាក់ នៅថ្ងៃទី៥ ខែវិច្ឆិកា ២០០៩។ អ្នកតំណាងរាស្ត្រ **យ៉ែម បុញ្ញឫទ្ធិ** មណ្ឌព្រៃវែងគណបក្សសិទ្ធិមនុស្សបានអញ្ជើញចុះ អមដំណើរឯកឧត្តម **កឹម សុខា** ប្រធានគណបក្សចូលរួមក្នុងពិធីប្រជុំសំណេះសំណាលជាមួយសមាជិកបក្ស នៅខេត្តព្រៃវែង នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩។

មណ្ឌលដែលខាងខុមហ្វ្រែលមិនបានទទួលព័ត៌មានពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមាន ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តឧត្តរមានជ័យ ខេត្តកែប និងខេត្តរតនគីរី។

# ការណែនាំអំពីហិរញ្ញវត្ថុគណបក្សនយោបាយ

ភាពប្រឈមនៃហិរញ្ញវត្ថុនយោបាយ នៅអាមេរិកឡាទីន

ការវិភាគប្រៀបធៀបនៅក្នុងតំបន់មួយនៃមូលនិធិគណបក្សនយោបាយនិងយុទ្ធនាការបោះឆ្នោតនៅអាមេរិក ឡាទីន...

San Jose, Costa Rica 2004

និពន្ធដោយ Steven Griner និង Daniel Zovatto

ប្រែសម្រួលក្រៅផ្លូវការដោយ៖ **ស្រី សុតវ្រ្ត**

បោះពុម្ពដោយ៖ អង្គការសហរដ្ឋអាមេរិក (OAS) និងវិទ្យាស្ថានអន្តរជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ និងជំនួយបោះឆ្នោត (International IDEA)

អត្ថបទនេះផ្តល់នូវការវិភាគប្រៀបធៀបក្នុងតំបន់មួយនៃប្រព័ន្ធមូលនិធិគណបក្សនយោបាយក្នុង១៨ប្រទេសនៅអាមេរិកឡាទីន។ យើងផ្តល់នូវការវាយតម្លៃជាទូទៅមួយនៃការរកឃើញសំខាន់ៗ និន្នាការនាពេលបច្ចុប្បន្ន ផលប៉ះពាល់ទៅលើគណបក្សនយោបាយ និងប្រជាធិបតេយ្យជាទូទៅ។ បន្ថែមពីនេះទៀតយើងនឹងបង្ហាញនូវគោលការណ៍ណែនាំមួយចំនួនមាន គោលដៅទូទៅ និងអនុសាសន៍មិនមែនជាបញ្ញត្តិ នៅក្នុងទស្សនៈរបស់យើងដែលគួរតែពិចារណានៅរាល់ដំណើរការកំណែទម្រង់នានា។

**( ត ពីលេខមុន ព្រឹត្តិប័ត្រអ្នកឃ្លាំមើលលេខ ៣៩ )**

**a- ប្រព័ន្ធរដ្ឋាភិបាល**

ដូចដែល Xiomara Navas-Carbo បាននិយាយសំដៅទៅដល់ ប្រព័ន្ធប្រធានាធិបតី បានទាក់ទងដោយផ្ទាល់ដល់ហិរញ្ញវត្ថុគណបក្ស។ ប្រព័ន្ធនយោបាយនៅអាមេរិកឡាទីន រួមបញ្ចូលភាពជាអ្នកដឹកនាំថ្នាក់ប្រធានាធិបតីជាមួយនឹងប្រព័ន្ធបោះឆ្នោតតាមសមាមាត្រ និងពហុគណបក្ស ទោះបីជាមានភាពសំខាន់ខុសគ្នាៗក្នុងទស្សនៈវិស័យនីមួយៗ។ វាគឺការបោះឆ្នោតរើសប្រធានាធិបតី មិនមែនការបោះឆ្នោតសភា ដែលកំណត់វិធីចំណាយច្រើនបំផុតសម្រាប់យុទ្ធនាការបោះឆ្នោត។ នេះមានផលប៉ះពាល់ដល់រចនាសម្ព័ន្ធនៃប្រតិលាភរបស់បេក្ខជន និងគណបក្សនយោបាយ ជាពិសេសទាក់ទងទៅនឹងវិភាគទានឯកជន ដែលជាទូទៅបង្កើតឡើងនូវមូលនិធិដុលត្រូវបានប្រើប្រាស់ជាយុទ្ធនាការហិរញ្ញវត្ថុ។

បឋមភាពនៃការបោះឆ្នោតរើសប្រធានាធិបតី ក្នុងប្រព័ន្ធទាំងនេះ មានន័យថា ដោយសារតែផលប្រយោជន៍នៃម្ចាស់ជំនួយ កំពុងកើនឡើងអានុភាពទៅលើការប្រជែងសម្រាប់មុខងារជាច្រើននៃអំណាចដ៏អស្ចារ្យ វិភាគទានឯកជន ឆ្ពោះទៅរកបេក្ខជនប្រធានាធិបតីដោយត្រង់ ឬក្រុមអ្នកគាំទ្រខាងក្នុង ច្រើនជាងរចនាសម្ព័ន្ធគណបក្សផ្លូវការ ។

**b- ប្រព័ន្ធគណបក្សនយោបាយ**

ខណៈដែលមានប្រព័ន្ធគណបក្សផ្សេងៗគ្នាដ៏អស្ចារ្យនៅក្នុងតំបន់ ភាគច្រើនមានគន្លឹះមួយនៅក្នុងប្រព័ន្ធធម្មតា៖ ឥទ្ធិពលនៃបុគ្គលនិយម (គឺនយោបាយផ្តោតទៅលើបេក្ខជន) ដែលបង្អាក់ការអភិវឌ្ឍនៃស្ថេរភាពគណបក្សពីគោលទស្សនៈនៃស្ថាប័ន រចនាសម្ព័ន្ធ និងប្រជាធិបតេយ្យ។ ចំណុចនេះ មានឥទ្ធិពលមិនត្រឹមតែលើមុខងារតួនាទី នៃប្រព័ន្ធគណបក្សប៉ុណ្ណោះទេ ប៉ុន្តែប៉ះពាល់ដល់វិធីដែលវិភាគទានឯកជនបានទាក់ទងជាមួយ ជាពិសេសអំឡុងពេលយុទ្ធនាការបោះឆ្នោត។ ដូចបានសម្គាល់ខាងលើវិភាគទានជាច្រើន គឺធម្មតាផ្តល់ដោយផ្ទាល់ទៅដល់បេក្ខជនមួយ ច្រើនជាងរចនាសម្ព័ន្ធគណបក្ស ហេតុនោះការបង្កើតឧបសគ្គពិតប្រាកដគឺ ជាការសាកល្បងត្រួតពិនិត្យលើហិរញ្ញវត្ថុនយោបាយ។

ការត្រួតពិនិត្យ និងត្រួតត្រា មានភាពស្មុគស្មាញក្នុងបរិបទនេះ តាំងពីការដាក់ទណ្ឌកម្មក្នុងប្រទេសភាគច្រើន

គឺជាមូលដ្ឋានដែលមានបំណងសម្រាប់គណបក្សនយោបាយ (ឬនៅក្នុងករណីខ្លះមន្ត្រីជាច្រើនទទួលខុសត្រូវលើមូលនិធិគណបក្ស)។ បទប្បញ្ញាច្រើន បេ

## ៥-ប្រៀបធៀបការវិភាគក្នុងតំបន់ ៖ វិធីវិទ្យានិពន្ធ និង វិធីភូមិសាស្ត្រ

ផ្នែកនេះ បង្ហាញនូវការប្រៀបធៀបមួយ ការពិនិត្យមូលនិធិនៃគណបក្សនយោបាយក្នុងតំបន់ និងយុទ្ធនាការបោះឆ្នោត ក្នុង ១៨ ប្រទេស នៅអាមេរិកឡាទីន ដែលបានគ្របដណ្តប់ដោយការសិក្សា។ ផ្នែកទីមួយ គឺ ការវិភាគ វិទ្យានិពន្ធ ជាមួយ ៥ បន្ទាត់ ៖ ប្រព័ន្ធមូលនិធិ សិទ្ធិប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ គណនីយភាពនិងការបញ្ចេញឱ្យដឹង ការត្រួតពិនិត្យមើលស្ថាប័ននិងប្រពន្ធ័នៃការដាក់ទណ្ឌកម្ម និងប្រព័ន្ធយេនឌ័រ និងមូលនិធិនយោបាយ។ ផ្នែកទីពីរ គឺ វិភាគភូមិសាស្ត្រ នៃតំបន់ ៣ គឺ អាមេរិកកណ្តាល (Central America) សាធារណរដ្ឋ Dominican Republic, Mexico and Panama, the Andean region, and the Southern Cone.

### ១-ការវិភាគវិទ្យានិពន្ធ

#### *ក-ហិរញ្ញវត្ថុនយោបាយ ៖ ប្រព័ន្ធសាធារណៈ ឯកជន និងចំរុះ*

ប្រទេសជាច្រើននៅអាមេរិកឡាទីន មានប្រពៃណីជាយូរមកហើយ នៃមូលនិធិសាធារណៈ។ ដូចជារបបនយោបាយជាច្រើន នៅអឺរ៉ុបខាងលិច ប្រព័ន្ធនេះបានជ្រើសរើសវិធីមួយដើម្បីចៀសវាង ឬបន្ថយឥទ្ធិពលនៃក្រុមដែលមានផលប្រយោជន៍ឯកជន និងអំណាចតាមជាក់ស្តែងនៅក្នុងការសម្តែងមុខងារគណបក្ស។ គោលដៅនៃមូលនិធិសាធារណៈ គឺ ដំបូង ដើម្បីផ្តល់នូវលក្ខខណ្ឌប្រកបដោយសមធម៌ ក្នុងចំណោមតួអង្គនយោបាយខុសៗគ្នា អំឡុងពេលដំណើរការបោះឆ្នោត និងទីពីរ ដើម្បីសម្រេចនូវតម្លាភាពនៃមូលនិធិដ៏សំខាន់ និងដូច្នេះ សម្រាលកម្រិតខ្ពស់នៃអំពើពុករលួយនយោបាយ ។[1]

គំនិតដែលនៅក្រោមមូលនិធិសាធារណៈគឺថា វាធានាកម្រិតគ្រប់គ្រាន់នៃធនធាន ដូច្នេះការប្រកួតប្រជែងបោះឆ្នោត នឹងជាក់លាក់ថា ជាការប្រកួតប្រជែងមួយដែលផ្តល់ឱ្យគ្រប់គណបក្សនយោបាយនូវឱកាសពិតប្រាកដមួយដើម្បីប្រជែងសម្រាប់ការចូលទៅកាន់មុខតំណែងរដ្ឋាភិបាល ឬតំណាងសភាលើមូលដ្ឋាននៃឱកាសស្មើគ្នា ច្រើនជាងពឹងផ្អែកតែលើទ្រព្យសម្បត្តិហិរញ្ញវត្ថុ ដែលអាចនឹងប្រែក្លាយយុទ្ធនាការបោះឆ្នោតទៅជា ក្បួនប្រជាធិបតេយ្យ ប៉ុណ្ណោះ ជាមួយនឹងការកំណត់ទុកជាមុននូវអ្នកឈ្នះ និងអ្នកចាញ់។ គោលដៅ គឺដើម្បីដាស់តឿន ដើម្បីកំណត់ភាពដែលអាចទៅកើត គ្រោះថ្នាក់ដែលមានមកជាមួយក្នុងការប្រកួតប្រជែងប្រជាធិបតេយ្យនៃគណបក្សនយោបាយ ប្រែក្លាយពីអ្នកទោស ទៅជាភ្នាក់ងារទីផ្សារដែលមានអំណាច និងទោះបីជាផលប្រយោជន៍ក្រុម កំពុងប្រតិបត្តិការលើជាយនៃ ច្បាប់។[2]

បន្ថែមលើការវែកញែកដែលយល់ស្របនឹងមូលនិធិរដ្ឋ គឺវាបានផ្តល់ឱ្យជាមួយនឹងបំណងបង្កើតប្រតិបត្តិការហិរញ្ញវត្ថុគណបក្ស លំហូរចំណូល និងចំណាយ តាមរយៈតម្លាភាព និងបានដឹងពីផ្លូវដែលជាប្រធានបទដើម្បីត្រួតពិនិត្យ និងពិនិត្យពិច័យដោយរតនាគារសាធារណៈ។ គំនិតគឺថា តាំងពីគណបក្ស ចំណាយអ្នកដែលជាប់ពន្ធជាប្រាក់ វាគឺងាយស្រួលដើម្បីធានាការប្រព្រឹត្តតាមជាមួយនឹងគោលការណ៍នៃតម្លាភាព និងការត្រួតពិនិត្យ។

មូលហេតុសំខាន់ដទៃទៀត សម្រាប់ណែនាំនូវមូលនិធិសាធារណៈនៅក្នុងអាមេរិកឡាទីន គឺជំនឿ ដែលគណបក្សនយោបាយដើរតួនាទីម៉ឺងម៉ាត់នៅក្នុងតំណាងប្រជាធិបតេយ្យ និងដូច្នេះរដ្ឋត្រូវតែធានាថា ពួកគេមានការគាំទ្រ និងតម្រូវធនធាន ដើម្បីបំពេញប្រតិបត្តិការរបស់ពួកគេ និងយុទ្ធនាការបោះឆ្នោត ព្រមទាំងស្ថាបនាកម្ម និង ពង្រឹងតួនាទីប្រជាធិបតេយ្យ។

ការរួមគ្នាជាមួយនឹងលក្ខន្តិកៈតាមផ្លូវច្បាប់ដែលគណបក្សនយោបាយរីករាយសព្វថ្ងៃនេះ មាននៅក្នុងច្បាប់នៃ

---

1 ដោយយោងទៅតាមការជួយឧបត្ថមរបស់វា គោលបំណងដទៃទៀតនៃមូលនិធិសាធារណៈ គឺដើម្បីថាមពលគណបក្សនយោបាយដោយសេរី ពី "ការបំបាក់មុខ កិច្ចការងារនៃការស្នើសុំថវិកា" អនុញ្ញាតឱ្យពួកគេជំនួសដើម្បីផ្តោតទៅលើការងារនយោបាយរបស់ពួកគេ។

2 Wolderberg (2003), pp. 20-21

ប្រទេសភាគច្រើនក្នុងតំបន់។ នៅអាមេរិកឡាទីន គណបក្សនយោបាយគឺត្រូវបានគេយល់ថាជា សមាគមឯកជន ដែលចូលរួមបំពេញ មុខងារសាធារណៈ ដើម្បីបម្រើផលប្រយោជន៍ទូទៅ ដោយហេតុនោះ ត្រូវប្រគល់ឱ្យពួកគេវិញនូវ សិទ្ធិស្របច្បាប់សម្រាប់មូលនិធិរដ្ឋ។

(**នៅមានត...**)

# សំណឹករឹតតែខ្លាំងឡើងនៃសេរីភាពនៅកម្ពុជា



រថយន្តប៉ូលិសដឹកលោក ហង់ ចក្រា ចេញពីតុលាការក្រុង

សេរីភាពនៅកម្ពុជាក្នុងឆ្នាំ ២០០៩ មិនអាចទទួលបានចំណាត់ថ្នាក់ល្អឡើយក្នុងរបាយការណ៍អង្គការសិទ្ធិមនុស្សជាតិ និងអន្តរជាតិ ដរាបណារដ្ឋាភិបាលនៅតែប្រកាន់ជំហរមិនអើពើនឹងការរំលោភបំពានសិទ្ធិនយោបាយមូលដ្ឋាន និងសេរីភាពពលរដ្ឋ។

ក្នុងរបាយការណ៍ថ្មីមួយរបស់អង្គការ Freedom House ដែលបានដាក់ចំណងជើងថា "សេរីភាពនៅក្នុងពិភពលោក ឆ្នាំ២០១០ ៖ ភាពសឹករឹករិលនៃសេរីភាពរឹតតែខ្លាំងឡើង ឬ Freedom in the World 2010 : Erosion of Freedom Intensifies" បានបង្ហាញថា ភាពសឹក រិចរឹលនៃសេរីភាពនៅតែបន្តមានលើពិភពលោក ដោយសារការដើរត្រឡប់ថយក្រោយនៅអាមេរិកឡាទីន អាហ្វ្រិក អតីតសហភាពសូវៀត និងមជ្ឈិមបូព៌ា នៅក្នុងនោះកម្ពុជាក៏មានឈ្មោះក្នុងប្រទេសដែលមាននិន្នាការបំព្រួញចុះក្រោម ផងដែរ ។

ក្នុងរបាយការណ៍របស់អង្គការ Freedom House បានបង្ហាញថា ការផ្លាស់ប្តូរស្ថានភាព និងកម្រិតសេរីភាពក្នុងប្រទេសកម្ពុជា មាននិន្នាការបំព្រួញចុះក្រោម ដោយសារតែការនិរទេសជនជាតិ អ៊ុយហ្គ័រ (Uighur) ដែលជាអ្នកស្វែងរកសិទ្ធិជ្រកអាស្រ័យទាំង ២២ នាក់ ទៅឲ្យប្រទេសចិន ក្នុងខែធ្នូ ឆ្នាំ២០០៩។ ប្រៀបធៀបនឹងសិទ្ធិនយោបាយរបស់ តៃវ៉ាន់ មានភាពប្រសើរពីលេខ ២ ទៅដល់លេខ ១ ដោយសារតែការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយដែលដឹកនាំទៅដល់ការកាត់ទោសអតីតមន្ត្រីជាន់ខ្ពស់ជាច្រើនរូប ការប្រកាសលែងទទួលស្គាល់សុពលភាពនៃសមាជិកសភាជាច្រើនរូប ពីព្រោះតែការទិញសន្លឹកឆ្នោត និងបើកកិច្ចស៊ើបអង្កេតលើបេក្ខជនជាង ២០០ នាក់ សម្រាប់បទចោទប្រកាន់ការទិញសន្លឹកឆ្នោតនៅក្នុងពេលបោះឆ្នោតក្នុងស្រុក។ តែបែរជាអត្រាសេរីភាពពលរដ្ឋតៃវ៉ាន់ ធ្លាក់ចុះពីលេខ ១ ទៅលេខ ២ វិញ ដោយសារ គុណវិបត្តិនៅក្នុងការការពារនៃសិទ្ធិចុងចោទពីបទព្រហ្មទណ្ឌ ដែលបានបង្ហាញអំឡុងពេលការកាត់ទោសប្រឆាំងអំពើពុករលួយ និងករណីឧក្រិដ្ឋកម្មល្បីល្បាញ ព្រមទាំងច្បាប់មួយដែលរំលោភលើបណ្ឌិតសភាសេរី ដោយការរារាំងបុគ្គលិក និងអ្នកប្រាជ្ញនៅ ក្នុងភាពងាយស្រួលនៃការបណ្តុះបណ្តាលជាសាធារណៈ ពីការចូលរួមនៅក្នុងសកម្មភាពនយោបាយពិតប្រាកដ។

ព្រមជាមួយគ្នានេះដែរ អង្គការសិទ្ធិមនុស្ស Human Rights Watch

ក៏បានចេញរបាយការណ៍ថា ការគោរពសិទ្ធិមនុស្សនៅកម្ពុជាកំពុងមានដំណើរថយក្រោយ ដោយសង្កត់ធ្ងន់ទៅលើការរំលោភសិទ្ធិមនុស្សជាច្រើនករណីដែលកំពុងកើតមានឡើង រួមមានការគាបសង្កត់ទៅលើសេរីភាពខាងសម្តែងមតិ ខណៈដែលរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយគណបក្សប្រជាជន គ្រប់គ្រងទាំងស្រុងនូវស្ថានីយ៍ទូរទស្សន៍ទាំងអស់ និងស្ថានីយ៍វិទ្យុភាគច្រើន។ ការស្រុតចុះនៃសិទ្ធិសេរីភាពមួយទៀតគឺការធ្វើច្បាប់គាបសង្កត់ កាត់បន្ថយការបញ្ចេញមតិយោបល់ ជាក់ស្តែង ក្រមព្រហ្មទណ្ឌថ្មី ដែលអាចផ្តន្ទាទោសដាក់ពន្ធនាគារ ចំពោះជនទាំងឡាយណាដែលហ៊ានរិះគន់ស្ថាប័នរដ្ឋផងដែរ ប្រសិនបើការនិយាយទិតៀននោះត្រូវបានរាប់បញ្ចូលជា បទបរិហារកេរ្តិ៍ ឬការផ្សព្វផ្សាយព័ត៌មានមិនពិត រីឯច្បាប់ស្តីពីការធ្វើបាតុកម្មតម្រូវឲ្យមានភាពស្មុគស្មាញជាច្រើន រួមទាំងការដាក់កំហិតការជួបជុំគ្នាជាដើម។

ក្នុងរបាយការណ៍របស់អង្គការ Human Rights Watch ដែលមានទាំងអស់ ៦១២ ទំព័រនេះ បានផ្តោតលើការរំលោភសិទ្ធិមនុស្សនៅជាង ៩០ ប្រទេស ដែលក្នុងនោះប្រទេសកម្ពុជារងការរិះគន់ថា រដ្ឋាភិបាលកម្ពុជាបានប្រើប្រព័ន្ធតុលាការខុសដោយបំបិទសំឡេងអ្នកប្រឆាំងរដ្ឋាភិបាលវាយប្រហារក្រុមអ្នកការពារសិទ្ធិមនុស្ស និងរឹតបន្តឹងសេរីភាពសារព័ត៌មាន ហើយបោះបង់ចោលកាតព្វកិច្ចអន្តរជាតិក្នុងកិច្ចការពារជនភៀសខ្លួនដែរ។ អង្គការ Human Rights Watch បញ្ជាក់ថា សកម្មជនការពារសិទ្ធិមនុស្សចំនួនជាង ៦០នាក់ នៅកម្ពុជា កំពុងរងគ្រោះ និងរងការចោទប្រកាន់ដោយមិនត្រឹមត្រូវពាក់ព័ន្ធនឹងការបណ្តេញ និងរឹបអូសយកដីធ្លី។



ក្រុមបាតុករត្រូវបានរាំងដោយប៉ូលីស

ចំណែកអង្គការសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ដែលនឹងចេញផ្សាយរបាយការណ៍វាយតម្លៃប្រចាំឆ្នាំ ២០០៩ ក្នុងខែមករាខាងមុខ ក៏ប្រាកដជាមិនមានចំណាត់ថ្នាក់ល្អសម្រាប់កម្ពុជាដែរ តាមរយៈសេចក្តីប្រកាសព័ត៌មានពីការរំលោភសិទ្ធិមនុស្សជាបន្តបន្ទាប់នៅក្នុងត្រីមាសចុង ក្រោយឆ្នាំ២០០៩ នេះ។

សេរីភាពនៅក្នុងពិភពលោក បានបែងចែកជា៣ផ្នែកធំៗ ដែលរៀបចំឡើងសម្រាប់ប្រទេសនីមួយៗ និងដែនដី រាប់បញ្ចូលនៅក្នុងលិបិក្រម ៖ សេរី សេរីដោយផ្នែក និងមិនសេរី។ ក្នុងន័យនេះ ប្រទេសសេរី គឺជាប្រទេសមួយដែលមានវិសាលភាពទូលាយសម្រាប់បើកចំហការប្រកួតប្រជែងនយោបាយ បរិយាកាសមួយដែលការគោរពសេរីភាពពលរដ្ឋ ឯករាជ្យជីវិតពលរដ្ឋជាសំខាន់ និងឯករាជ្យលើប្រព័ន្ធផ្សព្វផ្សាយ។ រីឯប្រទេសសេរីដោយផ្នែក គឺប្រទេសមួយដែលមានការកំណត់ក្នុងការគោរពសិទ្ធិនយោបាយ និងសេរីភាពពលរដ្ឋ។ រដ្ឋសេរីដោយផ្នែក រងផលប៉ះពាល់ជាញឹកញាប់ពីបរិស្ថាននៃអំពើពុករលួយ កំសោយនៃច្បាប់ជាតិពន្ធ និងវិវាទសាសនា ហើយតែងតែចាត់ទុកនៅក្នុងអ្វីដែលគណបក្សនយោបាយតែមួយរីករាយលើសលប់ ទោះបីជាពហុនិយមបានកំណត់ត្រឹមតែពីខាងក្រៅ។ ចំណែកប្រទេសមិនសេរី គឺជាប្រទេសមួយដែលអវត្តមានសិទ្ធិនយោបាយមូលដ្ឋាន និងមូលដ្ឋានគ្រឹះនៃសេរីភាពពលរដ្ឋ គឺបានបដិសេធន៍ក្នុងកម្រិតធំធេង និងឥតលម្អៀង។

ជាទូទៅសារសំខាន់បំផុតនៃការធ្លាក់ចុះសេរីភាពមាននៅក្នុងសង្វៀនច្បាប់ ដោយប្រព័ន្ធតុលាការទាំងស្រុងនៅតែខ្សោយ មិនអាចដើរតួនាទីដោយឯករាជ្យ ឬអនុវត្តច្បាប់ដោយស្មើគ្នាទៅគ្រប់សមាជិកទាំងអស់នៃសមាគម។ ការឃុំខ្លួនតាមតែទំនើងចិត្ត

និងការរំលោភសិទ្ធិមនុស្សដោយរដ្ឋ និងភាគីមិនមែនរដ្ឋ នៅតែបន្តមានដើម្បីប៉ះពាល់ដល់ដំណើរការឆ្ពោះទៅរកការបង្កើតផលចំណេញប្រជាធិបតេយ្យនៅក្នុងសង្គម។ តាមការវិភាគតាមដានស្ថានការណ៍នយោបាយកម្ពុជាមួយចំនួន បានចាត់ទុកប្រទេសកម្ពុជាស្ថិតក្នុងប្រទេស **សេរីដោយផ្នែក** ហេតុនេះខណៈដែលកម្ពុជាកំពុងស្ថិតក្នុងជំពូកប្រទេសសេរីដោយផ្នែក រដ្ឋាភិបាលគួរតែរៀនពីចំណុចខ្សោយនៃបណ្តាប្រទេសដែលសេរីភាពធ្លាក់ចុះ ដើម្បីស្តារមុខមាត់កម្ពុជាលើឆាកអន្តរជាតិ៕

**ដោយៈ អ្នកឃ្លាំមើល**

ស.ប្រ.ក.ព/លេខ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីអំពី
# រង្វាន់លើកទឹកចិត្ត អ្នកឃ្លាំមើលមូលដ្ឋាន

**ភ្នំពេញ ថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១០**

គណៈកម្មាធិការ(ខុមហ្វ្រែល) មានកត្តិយសជំរាបជូន សាធារណៈជនឱ្យបានជ្រាបថា ខុមហ្វ្រែល នឹងមានប្រារព្ធពិធីប្រគល់រង្វាន់ សំរាប់អ្នកឃ្លាំមើលមូលដ្ឋានចំនួន ០៤ រូប។អ្នកឃ្លាំមើលទាំង៤ រូបនេះគឺជា បណ្តាញរបស់ខុមហ្វ្រែលនៅថ្នាក់មូលដ្ឋានដែលពួកគេបានចូលរួមស្ម័គ្រចិត្ត ក្នុងការងារសង្កេត ឃ្លាំមើលក្រុម ប្រឹក្សាមូលដ្ឋាន។ ពួកគេបានចូលរួមបង្កើតការទំនាក់ទំនង ឬវេទិកាពិភាក្សារវាងប្រជាពលរដ្ឋជាមួយក្រុម ប្រឹក្សាឃុំ សង្កាត់។ ពួកគេត្រូវបានវាយតម្លៃ ឱ្យជាប់ចំណាត់ថ្នាក់ឆ្នើម លើការបំពេញកិច្ចការមូលដ្ឋាន នៅក្នុងឃុំ សង្កាត់របស់ពួកគេផ្ទាល់ សំរាប់ឆ្នាំ ២០០៨-២០០៩។ ក្រៅពីកិច្ចការខាងលើពួកគាត់ក៏បាន ផ្តួចផ្តើមគំនិត ជួយធ្វើអន្តរាគមន៍ ធ្វើរបាយការណ៍ និងជាអ្នកទំនាក់ទំនងពាំនាំព័ត៌មានពីប្រជាពលរដ្ឋ ទៅ ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយពីក្រុមប្រឹក្សាឃុំ សង្កាត់ ទៅប្រជាពលរដ្ឋវិញ និងកិច្ចការផ្សេងទៀតដែលបំរើ ឱ្យផលប្រយោជន៍ ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន។

នេះជាលើកទីមួយហើយដែល ខុមហ្វ្រែលបានរៀបចំការវាយតម្លៃដើម្បីផ្តល់រង្វាន់សំរាប់អ្នកឃ្លាំមើល មូលដ្ឋាននេះឡើង។ ដំណើរការនៃកម្មវិធីនេះមានរយៈពេលមួយខែគឺចាប់ផ្តើមពីដើមខែធ្នូ ហើយបញ្ចប់នៅចុងខែធ្នូ ឆ្នាំ ២០០៩។ការវាយតម្លៃបានរកឃើញមានអ្នកឃ្លាំមើលចំនួន ០៤រូបជាប់ចំណាត់ ថ្នាក់ពីលេខ១ ដល់ លេខ៣ និងម្នាក់ទៀតជាប់រង្វាន់លួងចិត្ត ត្រូវបានជ្រើសរើស ចេញពីបេក្ខជនចំនួន ៤២រូប មកពី ២១ រាជធានី ខេត្ត ដែលបានដាក់ពាក្យសុំធ្វើការប្រកួតប្រជែង។ ក្រុមការងារវាយតម្លៃរបស់ ខុមហ្វ្រែលបាន ចុះពិនិត្យដល់ មូលដ្ឋានដើម្បីសំភាសន៍ផ្ទាល់ជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និង ប្រជាពលរដ្ឋនៅឃុំ សង្កាត់របស់ពួកគេ

ឆ្លងតាមលទ្ធផលរបស់គណៈកម្មការវាយតម្លៃ លើការបំពេញកិច្ចការមូលដ្ឋាន យើងទទួលបានៈ




- ចំណាត់ថ្នាក់លេខ១ បានទៅលើ **លោក កន សារឧត្ត** ជាអ្នកឃ្លាំមើលមូលដ្ឋានមកពី ឃុំបន្ទាយនាង ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ដែលមានស្នាដៃអន្តរាគមន៍ លើបញ្ហាកើតមាននៅក្នុងឃុំ-សង្កាត់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ជួយដោះស្រាយ។




- ចំណាត់ថ្នាក់លេខ២ បានទៅលើ **លោក តាក លឹម** ជាអ្នកឃ្លាំមើលមូលដ្ឋានមកពី ឃុំពងទឹក ស្រុករំដួល ខេត្តស្វាយរៀង ដែលមានស្នាដៃលើការទំនាក់ទំនងល្អជាមួយ អាជ្ញាធរមូលដ្ឋាន។




- ចំណាត់ថ្នាក់លេខ៣ បានទៅលើ **លោក យ៉ាង ថន** ជាអ្នកឃ្លាំមើលមូលដ្ឋានមកពី ឃុំបាតាង ស្រុកលំផាត់ ខេត្តរតនគិរី មានស្នាដៃលើការចូលរួម កសាងសាលាប្រជុំភូមិ និងជំរុញការដោះស្រាយបញ្ហាដីធ្លី។

- រង្វាន់លួងចិត្ត បានទៅលើ **លោកស្រី មាស សុខេន** ជាអ្នកឃ្លាំមើលមូលដ្ឋានមកពី ឃុំតុងរ៉ុង ស្រុកព្រៃឈរ ខេត្តកំពង់ចាម លោកស្រីបានចូលរួមលើកសំណើប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីលើកបញ្ហា នៅមូលដ្ឋាន ។

កម្មវិធីផ្តល់រង្វាន់នេះ បានប្រព្រឹត្តទៅថ្ងៃទី២៧ ខែមករា ឆ្នាំ ២០១០វេលាម៉ោង២:០០នាទី នៅ ទីស្នាក់ការកណ្តាលខុមហ្វ្រែល ដែលមានការអញ្ជើញចូល រួមពីគណៈកម្មាធិការប្រតិបត្តិ គណៈកម្មការវាយតម្លៃ និងលេខារាជធានីខេត្តខុមហ្វ្រែលទាំង២។

សេចក្តីជូនដំណឹងនេះ ចាត់ទុកជាព័ត៌មានដល់សាធារណៈជូនជ្រាប។

**សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង**

- លោក **គឹម ឈន** អ្នកសម្របសម្រួលកម្មវិធីជាន់ខ្ពស់ខុមហ្វ្រែល ០១២ ៩៤២ ០១៩
- លោក **ប្លង បឿត** មន្ត្រីផ្នែកបណ្តាញ និងវេទិកាសាធារណៈ ០១២ ៤៧១ ៣២៦

**គណៈកម្មការព្រឹត្តិបត្រ**

| | |
|---|---|
| ១. លោក **គល់ បញ្ញា** | ទីប្រឹក្សាផ្តល់យោបល់ |
| ២. លោក **ច័ន្ទ ដារិទ្ធ** | ប្រធានសម្របសម្រួលព័ត៌មាន និងការផ្សាយ |
| ៣. លោក **ស្រី សុគន្ធ** | មន្ត្រីសម្របសម្រួលការនិពន្ធ និង ព្រឹត្តិបត្រ |
| ៤. អ្នកស្រី **រស់ ស៊ីណាក់** | សមាជិក |

អាសយដ្ឋាន
ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់១
ខណ្ឌទួលគោក រាជធានីភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រ ១១៤៥

| | |
|---|---|
| ទូរស័ព្ទ | ០២៣ ៨៨៤ ១៥០ |
| ទូរសារ | ០២៣ ៨៨៣ ៧៥០ |
| អ៊ីម៉េល | comfrel@online.com.kh |
| គេហទំព័រ | www.comfrel.org |

បើលោក អ្នកនាងកញ្ញាមានសំណួមពរ ចម្ងល់ ឬមានបំណងចូលរួមយោបល់ ឬស្នើសុំព្រឹត្តិបត្រសម្រាប់ស្ថាប័ន សូមទាក់ទងមកកាន់យើងខ្ញុំតាមរយៈអាសយដ្ឋានខាងលើនេះ។

ព្រឹត្តិបត្រ "អ្នកឃ្លាំមើល" ពីអង្គការសមាគម-មិនមែនរដ្ឋាភិបាល នៅដល់ដៃប្រជាពលរដ្ឋនៅទូទាំងប្រទេស ដើម្បីភ្ជាប់ចន្លោះព័ត៌មានរវាងប្រជាពលរដ្ឋ និងអ្នកតំណាង និងអ្នកដឹកនាំពាក់ព័ន្ធក្នុងការចូលរួមស្ថាបនាសង្គមប្រជាធិបតេយ្យ ។

# កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ ពីខែតុលា ដល់ខែ ធ្នូ ឆ្នាំ២០០៩

នយោបាយ និងសង្គម

- **ថ្ងៃទី ២៣ ខែតុលា ៖** ព្រះរាជាណាចក្រកម្ពុជាបានប្រកាសជំហររបស់ខ្លួនបដិសេធន៍ដាច់ខាតក្នុងការធ្វើបត្យាប័នបញ្ជូនលោក ថាក់ស៊ីន អតីតនាយករដ្ឋមន្ត្រីថៃ ត្រឡប់ទៅថៃវិញ ដោយចាត់ទុកថា **ជារឿងនយោបាយ** និងដាកាយវិកា

ចុះឈ្មោះបោះឆ្នោតរបស់ពលរដ្ឋជិត៤ពាន់នាក់ ដែលត្រូវផ្លាស់ទីលំនៅដោយបង្ខំទៅកាន់លំនៅដ្ឋានថ្មីនៅជាយក្រុងភ្នំពេញ ដោយសារមិនទាន់មានឯកសារបញ្ជាក់ទីលំនៅ។

- **ថ្ងៃទី ១០ ខែធ្នូ ៖** ក្រុមការងារនៃអង្គការសង្គមស៊ីវិល តំណាងស្ថានទូត សិស្ស និស្សិត ជនជាតិដើមភាគតិច និងសហជីពកម្មករ ប្រមាណជាង៥ពាន់ នាក់ បានមកជួបជុំគ្នាដើរដង្ហែក្បួនដោយសន្តិវិធី ពីបរិវេណវត្តភ្នំផ្នែកខាងកើត កាត់តាមបណ្តោយផ្លូវសុធារស ( ផ្លូវមាត់ទន្លេ ) ឆ្ពោះទៅកាន់ទីលានមុខវត្តបទុមវត្តី ដើម្បីអបអរទិវាសិទ្ធិមនុស្សអន្តរជាតិ ក្រោមប្រធានបទ "យើងទាំងអស់គ្នាត្រូវការសិទ្ធិសេរីភាពបញ្ចេញមតិ

ប្រភេទផងដែរ។ ការកំណត់ពន្ធបែបនេះ ត្រូវបានរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បញ្ជាក់ថា មិនប៉ះពាល់ដល់អ្នកក្រទេ ព្រោះយកពន្ធតែលើរថយន្ត ដី និងផ្ទះថ្លៃៗរបស់អ្នកមាន។

- នៅថ្ងៃទី ៨ ខែធ្នូ សាលា ំងូ រាជ ផ្នំពេញ លោក

អាយុ ៣៩ ឆ្នាំ និង បុរសឈ្មោះ ព្រំ ជា អាយុ ៤១ ឆ្នាំ ត្រូវបាន[illegible]លាការខេត្តស្វាយរៀង ចាប់ឃុំខ្លួន ក្រោមបទចោទប្រកាន់ដូចគ្នានឹងលោក សម រង្ស៊ី ខណៈពួកគេបានចូ[illegible]មកបង្ហាញខ្លួនតាមដីកាកោះរបស់ចៅក្រមស៊ើបសួរ។ ចំណែកអ្នកភូមិ ៣ នាក់ទៀត កំពុងតែរត់គេចខ្លួន។

- **ថ្ងៃទី ២៩ ខែធ្នូ ៖ ច្បាប់អស្សាមិករណ៍** ដែលមាន ៨ ជំពូក និង [illegible]៩ មាត្រា ត្រូវបានសមាជិករដ្ឋសភា មកពីគណបក្សប្រជាជនកម្ពុជាអនុម័តគាំទ្រតែអង្គឯងលើសម្លេង ៧៦[illegible]បី ១០០ ។ ច្បាប់នេះបានផ្តល់អំណាចឲ្យរដ្ឋាភិបាលអាចដកហូតនូវកម្មសិទ្ធិដីធ្លី និងអចលនៈទ្រព្យឯកជន បា[illegible]គ្រប់កាលៈទេសៈ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ។

## អភិបាលកិច្ច សេដ្ឋកិច្ច និងការអភិវឌ្ឍ

- **ថ្ងៃទី ២៩ ខែកញ្ញា ៖** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋ[illegible]ន្ត្រីក្រសួងទូរគមនាគមន៍ បានចុះ ហត្ថលេខារួមគ្នា ប្រកាសឲ្យក្រុមហ៊ុនទូរសព្ទ័ចល័តទាំងអស់បញ្ឈប់ការប[illegible]សនាផ្សព្វផ្សាយបញ្ចុះតម្លៃ ដើម្បីប្រជែងដណ្តើមទីផ្សារ និងការរាំងខ្ទប់ផ្នែកបច្ចេកទេសក្នុងការហៅឆ្លងប្រ[illegible]ន្ធ័មិនចូល ដើម្បីការពារវិបត្តិទូរគមនាគមន៍ និងចំណូលថវិការដ្ឋ ។
- **ថ្ងៃទី ១៩ ខែតុលា ៖** នៅក្នុងវេទិកាជាតិលើកដំបូង ស្តីពីការប្រែប្រួល[illegible]ាកាសធាតុ នៅទីក្រុងភ្នំពេញ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសផ្អាកគម្រោងយកពន្ធលើការ[illegible]ាប់វិទ្យុ និងមើលទូរទស្សន៍ពីប្រជាពលរដ្ឋដែលជាសំណើរបស់ប្រធានគណៈកម្មាធិការព័ត៌មានរដ្ឋសភា។ [illegible]ាកបានមានប្រសាសន៍ថា "ការលើកគំនិតនេះ (យកពន្ធពីវិទ្យុ និងទូរទស្សន៍) ល្អហើយ ដើម្បីបង្កើនចំណូ[illegible]ប ប៉ុន្តែខ្ញុំមិនទាន់បង្ខំទេ ខ្ញុំចង់ឲ្យប្រជាជនបានស្តាប់វិទ្យុ និងមើលទូរទស្សន៍ កុំអាលយកពន្ធពីគាត់អី"។

## សំឡេង[illegible]

# សកម្មភាពការងាររបស់គណៈកម្មាធិការខុមប្រែល



គណៈប្រតិភូខុមប្រែលជួបពិភាក្សាការងារជាមួយមន្ត្រីក្រសួងមហាផ្ទៃ



សិក្ខាសាលាស្តីពីម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៅខេត្តសៀមរាប



កិច្ចប្រជុំវាយតម្លៃការងារខុមប្រែលប្រចាំឆ្នាំ២០០៩





ការផ្សាយបន្តផ្ទាល់សំឡេងសង្គមស៊ីវិលរបស់ខុមប្រែលស្តីពីការលើកស្ទួយ
វិស័យពិការភាពនៅមូលដ្ឋាន